ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៧ លេខ ២ មិថុនា ឆ្នាំ២០១៣ តម្លៃ ១.៥០០៛

# កំណែទម្រង់វិស័យជលផលនៅតំបន់បឹងទន្លេសាប៖ ហានិភ័យ និងឱកាសសម្រាប់ការអនុវត្តគំនិតច្នៃប្រឌិតថ្មី[១]

សេចក្ដីប្រកាសរបស់ សម្ដេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០១២ ស្ដីពី ការលុបបំបាត់ប្រព័ន្ធឡូត៍នេសាទទឹកសាបឯកជនទាំងស្រុង ដែលជាកំណែទម្រង់វិស័យជលផលទឹកសាបលើកទី២ សម្រាប់តំបន់បឹងទន្លេសាប ពោលគឺតំបន់ផ្ដល់ផលនេសាទខ្ពស់ជាងគេបង្អស់នៅកម្ពុជា។ ទន្ទឹមគ្នានឹងការបង្កើត និងបង្កើនដែននេសាទសម្រាប់សហគមន៍ និងតំបន់អភិរក្សធនធានជលផល កំណែទម្រង់នេះ ក៏នៅមានជួបបញ្ហាប្រឈម និងការលំបាកក្នុងផ្នែកក្របខ័ណ្ឌស្ថាប័ន ព្រមទាំងនាំឲ្យកើតមានឡើងនូវជម្លោះថ្មីៗផងដែរ។

អត្ថបទសង្ខេបនេះ បង្ហាញលទ្ធផលទទួលបានពីដំណើរការស្រាវជ្រាវ និងកិច្ចសន្ទនានានា ដើម្បីស្វែងយល់ពីឱកាសល្អ និងហានិភ័យផុសចេញពីកំណែទម្រង់វិស័យជលផល និងដើម្បីគាំទ្រដល់ការអនុវត្តន៍គំនិតច្នៃប្រឌិតថ្មីនៅថ្នាក់មូលដ្ឋាន។ ដំណើរការនេះ បាននាំឲ្យមានសិក្ខាសាលាអំពីកំណែទម្រង់វិស័យជលផលក្នុងតំបន់បឹងទន្លេសាប រៀបចំដោយរដ្ឋបាលជលផល កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ដោយមានការចូលរួមពីតំណាងសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល NGOs និងមន្ត្រីស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាច្រើន។[២]



កិច្ចពិភាក្សាជាក្រុម ពីបញ្ហាជលផលនិងការគ្រប់គ្រងក្នុងពេលបច្ចុប្បន្ន នៅឃុំផាត់សណ្ដាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ ។

## កំណែទម្រង់ ហានិភ័យ និង ឱកាសល្អ៖

**កំណែទម្រង់វិស័យជលផលទាំងពីរលើក មានគោលដៅស្រដៀងគ្នា តែក្នុងបរិបទខុសគ្នា។** កំណែទម្រង់វិស័យជលផលទឹកសាបនាពេលថ្មីៗនេះ ដែលផ្ដួចផ្ដើមឡើងដោយរដ្ឋាភិបាលថ្នាក់លើ គឺជាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យជលផល ដ៏សំខាន់បំផុតមួយរបស់ប្រទេសកម្ពុជាក្នុងសម័យកាលនេះ ដើម្បីដោះស្រាយបញ្ហាការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍជនបទ។ កំណែទម្រង់លើកទី១ បានធ្វើឡើងក្នុងកំឡុងឆ្នាំ២០០០ និង ២០០១ ដោយលុបចោលផ្ទៃឡូត៍នេសាទក្នុងបឹងទន្លេសាបចំនួន ៥៦% ដើម្បីឲ្យទៅសហគមន៍ប្រើប្រាស់។ កំណែទម្រង់លើកទី២ ដែល

---

១ អត្ថបទនេះរៀបរៀងដោយលោក គឹម សួ ជាអ្នកស្រាវជ្រាវ និង លោក សូ សុវណ្ណារិទ្ធិ ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៃវិទ្យាស្ថាន CDRI, លោក ម៉ម កុសល និង Blake Ratner នៃមជ្ឈមណ្ឌលត្រីពិភពលោក (Worldfish), និងលោក អឿ អ៊ុល នៃមជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍(ADIC)។

២ សិក្ខាសាលាពិគ្រោះយោបល់ និងការស្រាវជ្រាវ ដើម្បីគ្រប់គ្រងធនធានជលផល នៅបឹងទន្លេសាប CDRI បានរៀបចំឡើងដោយសហការជាមួយរដ្ឋបាលជលផល, Worldfish និង ADIC, និងជាផ្នែកមួយនៃកម្មវិធីឆ្លងតំបន់ដ៏ធំ ហៅថា "ការពង្រឹងអភិបាលកិច្ចធនធានជលផល៖ ការអនុវត្តបែបថ្មីផ្នែកស្ថាប័ន ដើម្បីកសាងសន្តិសុខស្បៀង និងកាត់បន្ថយទំនាស់នៅតំបន់អេកូឡូស៊ីនៃបឹង Victoria, បឹង Kariba និងបឹងទន្លេសាប/មេគង្គក្រោម" ដែលទទួលបានហិរញ្ញប្បទានពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នៃប្រទេសអាឡឺម៉ង់។ ដៃគូសហការផ្សេងទៀត រួមមានវិទ្យាស្ថានស្រាវជ្រាវ Adelphi នៅក្រុង Berlin និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្នុងស្រុកពីរ គឺ FACT និង HOM ដែលជួយគាំទ្រដល់ការការអនុវត្តបែបថ្មី នៅថ្នាក់មូលដ្ឋាន ក្នុងខេត្តកំពង់ធំ។ របាយការណ៍ពេញលេញគ្រោងនឹងចេញផ្សាយក្នុងពេលឆាប់ៗ។

## មាតិកា

កំណែទម្រង់វិស័យជលផលនៅតំបន់បឹងទន្លេសាប៖ ហានិភ័យ និង ឱកាសសម្រាប់ការអនុវត្តគំនិតច្នៃប្រឌិតថ្មី ...១
តួនាទីវិនិយោគផ្ទាល់ពីបរទេស ក្នុងការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ....................................................៥
ករណីសិក្សា៖ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវនៅខេត្តតាកែវ ...........៩
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស .....................១៥
– ស្ថានភាពក្នុងប្រទេស.......................១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ......................................២៤

ប្រព្រឹត្តិទៅនៅដើមឆ្នាំ២០១២ បាននាំមកនូវការលុបបំបាត់ ឡូត៍នេសាទទឹកសាបជាលក្ខណៈឧស្សាហកម្ម ចោលទាំងស្រុង។ កាលលុបឡូត៍នេសាទ ក្នុងជំហានចុងក្រោយនេះ បានទទួលការអបអរសាទរពីសំណាក់អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងអ្នកនេសាទក្នុងមូលដ្ឋាន ដែលមានជីវភាពរស់នៅពឹងផ្អែកទាំងស្រុងលើការធ្វើនេសាទ នៅក្នុងដែននេសាទក្នុងបឹងទន្លេសាប។ កំណែទម្រង់វិស័យជលផលនេះ បានផ្តល់ឱកាសថ្មីៗ សម្រាប់ការគ្រប់គ្រងធនធានជលផលរួមគ្នា ដើម្បីលើកកម្ពស់ប្រាក់ចំណូលប្រជាជនមូលដ្ឋាន សន្តិសុខស្បៀង និងជីវភាពរស់នៅ។ ទោះជាយ៉ាងណា ក៏នៅមានការនេសាទ និងការប្រើប្រាស់ធនធានជលផលខុសច្បាប់ ដែលជាបញ្ហាចោទដ៏ធ្ងន់ធ្ងរផងដែរ។

កំណែទម្រង់វិស័យជលផលក្នុងឆ្នាំ២០០០ និង២០០១ បានអនុវត្តឡើងនៅពេលដែល ការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម កំពុងតែគ្របដណ្តប់លើផ្ទៃបឹងទន្លេសាបទាំងមូល ហើយមានបញ្ហាប្រើប្រាស់ និងទំនាស់ រវាងអ្នកនេសាទគ្រួសារ និងម្ចាស់ឡូត៍នេសាទ កាន់តែចោទខ្លាំងឡើង។ ការផ្លាស់ប្តូរពីការគ្រប់គ្រងបែបឧស្សាហកម្មទ្រង់ទ្រាយធំ ទៅជាការគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍ ដោយយោងតាមគោលការណ៍វិមជ្ឈការ នាំឲ្យមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ទៅលើសិទ្ធិរបស់អ្នកប្រើប្រាស់ធនធានជលផល។

កំណែទម្រង់វិស័យជលផល មានបំណងផ្តល់ឱកាសកាន់តែច្រើន ដល់អ្នកនេសាទនៅមូលដ្ឋានក្នុងការនេសាទត្រី និងដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ហើយក៏សំដៅការពារ និងអភិរក្សធនធានជលផល ឲ្យមានចីរភាពផងដែរ។ ក្នុងការអនុវត្តជាក់ស្តែង គោលដៅទាំងនេះ ជួនកាលវាប្រជែងគ្នា ហើយបង្កជាភាពតានតឹង ដែលបន្តរហូតមកដល់ដំណាក់កាលបច្ចុប្បន្ន ។

កំណែទម្រង់វិស័យជលផលឆ្នាំ២០១២នេះ មានបំណងកសាងបន្តលើកំណែទម្រង់ពីលើកមុន និងជាចំណែកមួយនៃយុទ្ធនាការដ៏ធំធេង ដែលព្យាយាមដោះស្រាយទំនាស់កើតមានជារឿយៗនៅជុំវិញបឹងទន្លេសាប។ បញ្ហាត្រូវដោះស្រាយ រួមមានសំណើពង្រីកលទ្ធភាពរបស់សហគមន៍ ក្នុងការប្រើប្រាស់តំបន់នេសាទឲ្យមានភាពជាក់លាក់ ការថយចុះផលនេសាទចាប់បាន និងទំនាស់រវាងអ្នកនេសាទនឹងម្ចាស់ឡូត៍នេសាទ។ចំណុចសំខាន់មួយទៀត គឺរដ្ឋាភិបាលបានទទួលស្គាល់ថា ចំណូលដែលបានពីការជួលឡូត៍នេសាទបែបឧស្សាហកម្មចំពោះសេដ្ឋកិច្ចជាតិ វាមិនចាំបាច់ជាងការរកផលនេសាទ សម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជានេសាទជាលក្ខណៈគ្រួសារនោះឡើយ។

**ការប្រញាប់ប្រញាល់ពេកក្នុងការចេញបទបញ្ញត្តិថ្មីៗ បានបង្កនូវភាពភ័ន្តច្រឡំនិងការមិនពេញចិត្ត។** នៅក្នុងកំណែទម្រង់ទាំងពីរលើក គឺមានការប្រកាសលុបឡូត៍នេសាទជាមុន ទើបមានកំណត់នូវយន្តការ (អនុក្រឹត្យ ឬប្រកាស) សម្រាប់គ្រប់គ្រងកន្លែងអតីតឡូត៍នេសាទទាំងនោះ ជាក្រោយ។ កំណែទម្រង់លើកទី១ បានធ្វើឲ្យមានការបើកចំហទាំងស្រុង នូវការប្រើប្រាស់ធនធានជលផល (effectively open access) ក្នុងដំណាក់កាលដំបូង ហើយបន្ទាប់មកមានការអនុវត្តសាកល្បងជាច្រើនឆ្នាំ លើការបង្កើតសហគមន៍នេសាទ។ ប៉ុន្តែ ដោយក្របខ័ណ្ឌច្បាប់មានកម្រិតទន់ខ្សោយនៅឡើយនោះ ក៏ឲ្យមានភាពចន្លោះប្រហោង ដែលនាំឲ្យការធ្វើនេសាទបែបឧស្សាហកម្ម បន្តដំណើរការបាន ហើយសឹងតែរុញច្រានអ្នកនេសាទជាលក្ខណៈគ្រួសារចេញពីតំបន់នេសាទដែលសម្បូរត្រីទាំងស្រុង។ ក្នុងកំណែទម្រង់វិស័យជលផលក្នុងឆ្នាំ២០១២នេះ គេឃើញមានបរិធានច្បាប់ថ្មីៗ និងសេចក្តីសម្រេចអំពីការកំណត់ឡើងវិញនូវ ដែននេសាទទឹកសាប បានកើតមានឡើងក្នុងរយៈពេលពីរបីខែ ក្រោយពីសេចក្តីប្រកាសរបស់សម្តេចនាយករដ្ឋមន្ត្រី។ លើសពីនេះ គេឃើញមានបង្កើតក្រុមការងារចម្រុះ ដើម្បីចុះបង្ក្រាបនិងដោះស្រាយបញ្ហានៅគ្រប់ទិសទី ដែលទាក់ទងនឹងការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម លក្ខណៈសិប្បកម្ម និងលក្ខណៈគ្រួសារ ដែលត្រូវបានចាត់ទុកថា ជាការនេសាទខុសច្បាប់ និងបង្កការបំផ្លិចបំផ្លាញដល់ធនធានមច្ឆជាតិ។ កំណែទម្រង់វិស័យជលផលចុងក្រោយនេះ បានបែងចែកអតីតឡូត៍នេសាទ ក្នុងតំបន់បឹងទន្លសាបប្រមាណ ៦៥% ទៅឲ្យសហគមន៍នេសាទ (Community Fisheries - CFi) និងប្រមាណ ៣៥% ទៀត សម្រាប់ធ្វើជាតំបន់អភិរក្សធនធានជលផល។

មនុស្សជាច្រើនបានសាទរ ចំពោះការលុបបំបាត់ឡូត៍នេសាទជាស្ថាពរក្នុងតំបន់បឹងទន្លេសាប ប៉ុន្តែនៅមានចំណុចមិនរលូនគ្នា ឬភាពប្រទាំងប្រទើសជាច្រើន រវាងអនុក្រឹត្យថ្មី មាត្រាមួយចំនួននៅក្នុងច្បាប់ជលផល និងបទបញ្ញត្តិផ្សេងៗ ដែលបានធ្វើឲ្យមានភាពភាន់ច្រឡំក្នុងចំណោមអ្នកគ្រប់គ្រងធនធានជលផល និងអ្នកនេសាទនៅថ្នាក់មូលដ្ឋាន។ ភាពមិនរលូនគ្នា និងភាពចន្លោះប្រហោងទាំងនេះ បានធ្វើឲ្យបទបញ្ញត្តិច្បាប់មានលក្ខណៈស្រពេចស្រពិល អាចបកស្រាយបានច្រើនយ៉ាង និងពិបាកយកទៅអនុវត្តនៅក្នុងស្ថានភាពជាក់ស្តែង។ ប្រភពនៃភាពភាន់ច្រឡំនិងទំនាស់រួមមាន ការកំណត់ព្រំដែននេសាទ ការបញ្ជាក់ពីទំហំនៃដែននេសាទសហគមន៍ ការកំណត់និយមន័យនិងចំណាត់ថ្នាក់ ពីប្រភេទឧបករណ៍នេសាទ ដែលត្រូវបានអនុញ្ញាតប្រើប្រាស់ឲ្យបានច្បាស់ បទបញ្ញត្តិស្តីពីទំហំក្រឡាមងដែលអនុញ្ញាតឲ្យប្រើប្រាស់ និងការបញ្ជាក់ពីតួនាទីនិងទំនួលខុសត្រូវ របស់អាជ្ញាធរគ្រប់គ្រង និងប្រតិបត្តិច្បាប់។

**សកម្មភាពនេសាទស្ទុះឡើងយ៉ាងលឿន ដោយអាចនឹងជួបហានិភ័យថ្មីៗទៀត៖** កំណែទម្រង់វិស័យជលផលឆ្នាំ២០១២ បានជួយឲ្យអ្នកនេសាទនៅថ្នាក់មូលដ្ឋាន មានលទ្ធភាពធ្វើនេសាទបានច្រើនជាងមុន។ ដោយនឹកឃើញពីកំណើនសកម្មភាពនេសាទដ៏ខ្លាំងក្លា ក្រោយពីពេលធ្វើកំណែទម្រង់លើកទី១ និងការផ្អាកការពង្រឹងអនុវត្តន៍ច្បាប់អស់មួយរយៈមកនោះ អ្នកនេសាទជាច្រើនបានប្រញាប់ប្រញាល់ធ្វើវិនិយោគលើ ឧបករណ៍នេសាទខ្នាតធំ (ដែលភាគច្រើនជាឧបករណ៍បំផ្លិចបំផ្លាញដល់ធនធានជលផល) ដើម្បីឆ្លៀតឱកាសយកប្រយោជន៍ពី ស្ថានភាពច្របូកច្របល់ក្រោយពីធ្វើកំណែទម្រង់ភ្លាមៗនាពេលនោះ។ ប៉ុន្តែមិនបានយូរប៉ុន្មាន មន្ត្រីជំនាញ បានហាមឃាត់ និងដកហូតឧបករណ៍នេសាទខុសច្បាប់ទាំងនោះអស់ជាច្រើន។

បច្ចុប្បន្ននេះ ថ្វីបើប្រជានេសាទ អាចធ្វើនេសាទបាននៅក្នុង

ដែននេសាទជាច្រើនក៏ដោយ ក៏នៅមានរបាយការណ៍ថាមានអ្នកនេសាទមូលដ្ឋានក្រីក្រជាច្រើននាក់ នៅតែមិនទាន់អាចដកយកធនធានជលផលទាំងនោះ ឲ្យបានទាន់គេ ដោយសារតែពួកគាត់ពុំមានថវិកាគ្រប់គ្រាន់ ទិញឧបករណ៍នេសាទយកមកប្រើប្រាស់។ កំណែទម្រង់នេះ ក៏អាចបង្កើតជាហានិភ័យដល់ផ្នែកអេកូឡូស៊ីថ្មីៗថែមទៀត ព្រោះមានប្រជាជនកាន់តែច្រើនឡើងៗ ទៅធ្វើនេសាទពិសេសនៅតាមតំបន់បឹងព្រៃកជុំវិញបឹងទន្លេសាប ដែលមានទឹកជន់លិចនៅរដូវវស្សា ទាំងនេះគឺជាការដាក់សម្ពាធកាន់តែខ្លាំងទៅលើទីជម្រកត្រីដែលងាយនឹងរងនូវការប៉ះពាល់។

**បញ្ហាប្រឈម និងឱកាសថ្មីៗសម្រាប់សហគមន៍នេសាទ៖** គណៈកម្មាធិការសហគមន៍នេសាទភាគច្រើន មិនទាន់បានត្រៀមខ្លួនជាស្រេច ក្នុងន័យលក្ខណៈបច្ចេកទេស និងក្របខ័ណ្ឌស្ថាប័ន ដើម្បីទទួលខុសត្រូវលើការគ្រប់គ្រងដែននេសាទរបស់ខ្លួន ដែលកាន់តែធំនោះឡើយ។ ថ្វីបើសហគមន៍នេសាទទាំងអស់នៅតំបន់បឹងទន្លេសាបបានចុះបញ្ជីរួចហើយក្តី ប៉ុន្តែមានសហគមន៍ជាច្រើនអាចនៅខ្វះខាតលើការយល់ដឹងពីសិទ្ធិស្របច្បាប់ តួនាទី និងទំនួលខុសត្រូវរបស់ខ្លួន ហើយអាចមានសមាជិកគណៈកម្មាធិការមួយចំនួននៅខ្វះការតាំងចិត្ត និងអាចមានភាពទន់ខ្សោយ ក្នុងការលើកកម្ពស់ចំណាប់អារម្មណ៍របស់សហគមន៍ខ្លួន និងក្នុងការសហការជាមួយស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធទាំងអស់។លើសពីនេះ វាក៏អាចធ្វើឲ្យថយចុះនូវការឧបត្ថម្ភលើកទឹកចិត្ត ក្នុងការខិតខំប្រឹងប្រែងធ្វើការងារគ្រប់គ្រង និងការពារតំបន់នេសាទសហគមន៍ នៅពេលដែលមានការពង្រីក និងបង្កើនបរិមាណនិងទំហំដែននេសាទសម្រាប់អ្នកនេសាទគ្រួសារ នៅក្នុងបឹងទន្លេសាប។ គណៈកម្មាធិការដឹកនាំសហគមន៍នេសាទក៏បារម្ភដែរថា ដែននេសាទសហគមន៍ដែលបង្កើត និងបង្កើនថ្មីៗ និងបែងចែកមកឲ្យសហគមន៍គ្រប់គ្រងនោះវាអាចមានទំហំធំហួសពីសមត្ថភាពគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ គណៈកម្មាធិការសហគមន៍។

កំណែទម្រង់ច្បាប់ និងគោលនយោបាយ គឺជាការចាំបាច់សម្រាប់ដោះស្រាយបញ្ហាប្រឈម និងការលំបាកទាំងឡាយដែលទាក់ទងនឹង ការគ្រប់គ្រងធនធានជលផលដោយមានចីរភាព និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជានេសាទ ក្នុងតំបន់បឹងទន្លេសាបឲ្យបានធូរធាររីកចម្រើន ប៉ុន្តែកំណែទម្រង់ច្បាប់ និងគោលនយោបាយនេះហាក់នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ វាជាការសំខាន់ណាស់ ដែលត្រូវមានសកម្មភាពកសាងសមត្ថភាពតួអង្គពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ដោយរួមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងផ្នែកពាក់ព័ន្ធផ្សេងទៀត (ឧទាហរណ៍ ផ្នែកនេសាទ ផ្នែកវារីវប្បកម្ម និងផ្នែកអភិរក្សធនធានជលផល) និងរវាងដែនសមត្ថកិច្ចនានា (ឧទាហរណ៍ ពីកម្រិតភូមិ ទៅដល់កម្រិតបឹងទន្លេសាបទាំងមូល) ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ ។ ក្នុងន័យនេះ សំណួរសំខាន់ៗមួយចំនួន ដែលត្រូវដោះស្រាយ រួមមាន៖

- **ការពង្រឹងសមត្ថភាពអនុវត្តន៍ច្បាប់៖** តើការត្រួតពិនិត្យតាមដានលើការធ្វើនេសាទ និងការអនុវត្តច្បាប់ ត្រូវបានពង្រឹងឡើងយ៉ាងណា ដើម្បីទ្រទ្រង់ដល់ការអនុវត្តគោលនយោបាយថ្មី?
- **វិធានការណ៍អភិរក្សធនធានជលផល៖** តើយើងត្រូវកែប្រែអ្វីខ្លះដល់ទីជម្រកត្រី និងតំបន់ការពារធម្មជាតិ ដើម្បីទ្រទ្រង់ដល់ការស្តារប្រព័ន្ធអេកូឡូស៊ីឲ្យបានល្អឡើងវិញ? តើកិច្ចប្រឹងប្រែងរបស់សហគមន៍នេសាទ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ត្រូវសម្របសម្រួលគ្នាយ៉ាងណា ដើម្បីទ្រទ្រង់ដល់ការអភិរក្សធនធានជលផល?
- **ការពង្រឹងសហគមន៍នេសាទ៖** តើសិទ្ធិអំណាច និងសមត្ថភាពសហគមន៍នេសាទត្រូវពង្រឹងឡើងយ៉ាងណា? តើគួរតម្រង់ទិសសហគមន៍នេសាទទាំងនេះ ទៅជាបែបណា ដើម្បីលើកកម្ពស់ជីវភាពសមាជិកសហគមន៍ ហើយព្រមគ្នានេះ ដើម្បីធានាឲ្យបាននូវការប្រើប្រាស់ធនធានជលផលឲ្យមានចីរភាព?

## ផ្នែកដែលគួរអនុវត្តតាមគំនិតច្នៃប្រឌិតថ្មី

**ការធ្វើបច្ចុប្បន្នភាព និងការបញ្ជាក់បំភ្លឺលើ បទបញ្ញត្តិនេសាទនានា៖** ប្រកាសលេខ១២៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ឧបករណ៍នេសាទគ្រួសារ ត្រូវបានអនុម័តចេញភ្លាមៗ ដើម្បីជំរុញការអនុវត្តតាមកំណែទម្រង់គោលនយោបាយថ្មី។ ប៉ុន្តែដោយប្រកាសនេះត្រូវបានដាក់អនុវត្តន៍ ដោយមានការពិគ្រោះយោបល់តិចតួចពេក និងត្រូវបានបង្កើតឡើងតាមបែបផែនមួយ ដែលពុំបានគិតគូរពីបរិបទខុសៗគ្នាទៅតាមតំបន់ ដូច្នេះវិធានការនេះ ឬប្រកាសលេខ១២៩នេះ មិនបានដោះស្រាយ ឬឆ្លើយតបនឹងទំនាស់ ឬបញ្ហាទាក់ទងនឹងការប្រើឧបករណ៍នេសាទដែលត្រូវបានអនុញ្ញាត ដើម្បីផ្តល់ជាមូលដ្ឋានមួយសម្រាប់ការពង្រឹងការអនុវត្តច្បាប់ឲ្យបានរលូន។ ដំណើរការធ្វើវិសោធនកម្មក្របខ័ណ្ឌច្បាប់ គួរតែប្រព្រឹត្តិទៅដោយមានការចូលរួមក្នុងការពិគ្រោះយោបល់ អំពីអ្នកពាក់ព័ន្ធនានា ជាពិសេសអ្នកនេសាទនៅតាមមូលដ្ឋាន និងអ្នកទទួលផលពីធនធានជលផលឯទៀតដែលរស់នៅជុំវិញបឹងទន្លេសាប ដើម្បីចាប់យកគំនិត ទស្សនៈ និងបំណងប្រាថ្នារបស់ប្រជាជនមូលដ្ឋាន សំដៅធ្វើឲ្យបទបញ្ញត្តិជលផល មានខ្លឹមសារសមស្របនឹងស្ថានភាពបច្ចុប្បន្ននៃការធ្វើនេសាទ និងតម្រូវការការពារធនធានជលផល ហើយអាចយកទៅអនុវត្តបានដោយមានប្រសិទ្ធភាពខ្ពស់។

លើសពីនេះ ការបញ្ជាក់ឲ្យបានច្បាស់លាស់ ពីដែនកំណត់នៃការធ្វើនេសាទជាលក្ខណៈគ្រួសារ អាចចាត់ទុកជាលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងធនធានជលផលតាមជម្រើសណាមួយឲ្យបានជោគជ័យ ពីព្រោះវាអាចជួយពង្រឹងវិធានការអនុវត្តច្បាប់ និងអភិរក្សធនធានជលផល។ ទោះជាយ៉ាងណា ហានិភ័យចម្បងៗដែលទាក់ទងនឹងការកែប្រែបទបញ្ញត្តិគឺការអាចមានលេចចេញជាទំនាស់ថ្មីៗ និងអាចនាំឲ្យមានវិនិយោគិនលើឡូត៍នេសាទវិលត្រឡប់មកវិញ ហើយធ្វើការកេងប្រវ័ញ្ចយកផលប្រយោជន៍ ពីធនធានជលផលរបស់សហគមន៍នេសាទសាជាថ្មីម្តងទៀត។

**ការពង្រឹងទំនាក់ទំនងរវាងសហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន៖** ការកសាងភាពជាដៃគូរវាងសហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន អាចបង្កើតនូវលក្ខខណ្ឌផ្សេងៗ សម្រាប់ឲ្យសហគមន៍នេសាទអាចធ្វើការជាមួយគ្នា ដើម្បីសម្រេចគោលដៅ

រួម នៃការអភិរក្សធនធានជលផល ការពង្រឹងការអនុវត្តច្បាប់ និងការកសាងជីវភាពរស់នៅរបស់ប្រជាជន ឲ្យកាន់តែមានប្រសិទ្ធភាព និងកាន់តែប្រសើរឡើង។ ពិសេសទៅទៀត ការដាក់បញ្ចូលគ្នានូវផែនការរបស់សហគមន៍នេសាទ ទៅក្នុងផែនការវិនិយោគឃុំ-សង្កាត់ វាអាចជួយផ្ដល់ជាការគាំទ្រផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទនៅក្នុងឃុំ-សង្កាត់នោះ ហើយដែលនឹងអាចជួយពង្រឹងដល់គោលដៅ នៃគោលនយោបាយវិមជ្ឈការនាពេលបច្ចុប្បន្ន។ ការធ្វើសមាហរណកម្មនេះ គឺជាមធ្យោបាយមួយ សម្រាប់ជួយដោះស្រាយបញ្ហាប្រជែងដណ្ដើមធនធានគ្នា រវាងវិស័យជលផល និងវិស័យផ្សេងៗទៀតផងដែរ ជាពិសេសទំនាស់ដែលតែងតែកើតមានឡើងលើការរានព្រៃលិចទឹក ការពង្រីកដីធ្វើស្រែប្រាំង ការបែងចែកទឹកនៅរដូវប្រាំង និងការការពារ ឬការស្ដារឡើងវិញនូវព្រៃលិចទឹក។ ទោះជាយ៉ាងណាក៏ដោយ ក៏មានហានិភ័យនានាដែលពាក់ព័ន្ធនឹងសមាហរណកម្មនេះ រួមមាន គណៈកម្មាធិការសហគមន៍នេសាទ អាចបាត់បង់ឯករាជ្យភាពក្នុងដំណើរការនេះ នៅពេលមានតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់មកចូលរួម សហគមន៍នេសាទអាចខ្វះការលើកទឹកចិត្តក្នុងការកសាង សំណើដ៏រឹងប៉ឹងមួយឲ្យធ្វើវិនិយោគទៅលើ ការគ្រប់គ្រងធនធាននៅក្នុងឃុំ-សង្កាត់ ពីព្រោះវាផ្ទុយគ្នានឹងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្លាប់តែផ្ដល់អាទិភាពឲ្យនោះ។

**ការពង្រឹងការអនុវត្តច្បាប់ និងការយាមល្បាតរួមគ្នា៖** ការពង្រឹងការអនុវត្តច្បាប់ជលផល ក្នុងដែននេសាទ និងដែនអភិរក្ស ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន រដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត អាចជួយលើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព នៃកិច្ចប្រឹងប្រែងក្នុងការពង្រឹងការអនុវត្តច្បាប់នេះ។ ដោយសារស្ថាប័ននីមួយៗមានចំណុចខ្លាំង និងខ្សោយរៀងៗខ្លួន ដូច្នេះការធ្វើការរួមគ្នាបែបនេះជួយបំពេញឲ្យគ្នាទៅវិញទៅមក ហើយអាចផ្ដល់លទ្ធផលល្អ ក្នុងកិច្ចប្រឹងប្រែងលុបបំបាត់ការនេសាទខុសច្បាប់។

នៅក្នុងតំបន់ដែលមានការធ្វើស្រែប្រាំង និងតំបន់ការពារធនធានជលផលដោយសហគមន៍ ការអនុវត្តច្បាប់ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋាន មានសារៈសំខាន់ជាខ្លាំង ។ នៅតាមតំបន់ព្រៃលិចទឹកមួយចំនួន ភាពតានតឹងរវាងកសិករស្រែប្រាំង ជាមួយនឹងសហគមន៍នេសាទ បានកើនឡើងខ្លាំង ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ទឹក ក្នុងការប្រើប្រាស់ដី និងការការពារតំបន់ព្រៃលិចទឹក។ ក្នុងកាលៈទេសៈបែបនេះ ឆន្ទៈនយោបាយរបស់អាជ្ញាធរមូលដ្ឋាន មានតួនាទីដ៏សំខាន់ក្នុងការជួយគាំទ្រដល់កិច្ចសម្របសម្រួល និងសហការគ្នាក្នុងការដោះស្រាយ និងពង្រឹងការអនុវត្តច្បាប់។

**ការពិចារណា ទៅលើរបៀបគ្រប់គ្រងធនធានជលផលបែបថ្មី នៃសហគមន៍ផលិតកម្ម៖** នាពេលថ្មីៗនេះ គំនិតច្នៃប្រឌិតបែបថ្មីនៃសហគមន៍ផលិតកម្ម បាននិងកំពុងក្លាយជាគំរូមួយដែលអាចបង្កើនការលើកទឹកចិត្ត និងការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងដោយសមាជិកសហគមន៍នេសាទ។ វិធីសាស្ត្របែបថ្មីនេះ មិនទាន់អាចសមស្របសម្រាប់គ្រប់តំបន់ក៏ពិតមែន ក៏ប៉ុន្តែ វាគួរឲ្យយកមកពិចារណាផងដែរ នៅពេលដែលមានធនធានជលផលជាសក្ដានុពលសម្រាប់ឲ្យ សហគមន៍នេសាទធ្វើអាជីវកម្មក្នុងលក្ខណៈឧស្សាហកម្ម នៅក្នុងដែននេសាទសហគមន៍ដោយមានចីរភាព។ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់កាលពីខែធ្នូ ឆ្នាំ២០១២ អ្នកតំណាងសហគមន៍នេសាទបានបង្ហាញពីចំណាប់អារម្មណ៍ ចំពោះវិធីសាស្ត្របែបថ្មីនេះ ហើយបញ្ជាក់ថាវាជាមធ្យោបាយមួយ ដើម្បីបង្កើតចំណូលសម្រាប់ដោះស្រាយលើចំណាយប្រតិបត្តិការរបស់ សហគមន៍នេសាទ ពិសេសកិច្ចប្រឹងប្រែងបន្ថែម ដើម្បីការពារ និងគ្រប់គ្រងដែននេសាទសហគមន៍ ដែលមានទំហំធំ។ ការបង្កើតចំណូលសហគមន៍សម្រាប់ការគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍ផលិតកម្មអាចផ្ដល់ជាកម្លាំងចិត្តដល់សមាជិកសហគមន៍ ឲ្យចូលរួមកាន់តែច្រើននិងមានប្រសិទ្ធភាពឡើង ក្នុងការងារគ្រប់គ្រងរួមគ្នា ដោយឈរលើគោលការណ៍ជាមូលដ្ឋាននៃ ការលើកស្ទួយជីវភាពរស់នៅរបស់សមាជិកសហគមន៍នេសាទ។

ទោះជាយ៉ាងណាក៏ដោយ ក៏របៀបគ្រប់គ្រងធនធានជលផលបែបថ្មី នៃសហគមន៍ផលិតកម្មនេះ នឹងអាចមានជួបឧបសគ្គនិងការលំបាកជាច្រើន ដែលរារាំងដល់ការអនុវត្តក្នុងលក្ខណៈជាក់ស្ដែង។ មន្ត្រីរដ្ឋាភិបាលនៅមិនទាន់ទុកចិត្តទៅលើគំនិតបែបថ្មីនៅតាមមូលដ្ឋាន ក្នុងការបង្កើតចំណូលសហគមន៍នៅឡើយទេ ហើយតែងតែចោទសួរថា តើគំនិតបែបថ្មីទាំងនេះ វាស្របទៅតាមគោលការណ៍ច្បាប់ក្នុងកម្រិតណាដែរ ហើយត្រូវការពេលយូរប៉ុណ្ណា ដើម្បីដាក់អនុវត្តវិធីសាស្ត្រគ្រប់គ្រងបែបនេះក្នុងលក្ខណៈជាក់ស្ដែង។ ហើយក៏នៅមានបញ្ហាមិនទាន់ដោះស្រាយរួចមួយចំនួនទៀត រួមមាន៖ ១) តើផ្ទៃដែននេសាទសហគមន៍មានទំហំធំប៉ុណ្ណា ដែលស័ក្តិសមនឹងសមត្ថភាពគ្រប់គ្រង របស់គណៈកម្មាធិការសហគមន៍នេសាទ ២) កម្រិតនៃសិទ្ធិអំណាចរបស់គណៈកម្មាធិការសហគមន៍នេសាទ ក្នុងនេះមានទាំងសិទ្ធិហាមឃាត់អ្នកនេសាទ និងអ្នកប្រើប្រាស់ធនធានជលផល ដែលចូលមកពីខាងក្រៅផង ៣) តើប្រាក់ចំណូលដែលរកបានពីការធ្វើសហគមន៍ផលិតកម្ម ត្រូវគ្រប់គ្រងយ៉ាងដូចម្ដេច ហើយផលប្រយោជន៍នេះត្រូវបែងចែកយ៉ាងណា ដល់សមាជិកសហគមន៍ទាំងមូល ៤) តួនាទី និងទំនួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងការចូលរួមគ្រប់គ្រងរួមគ្នា ការពិនិត្យតាមដានការបង្កើតវិធានការផ្សេងៗ និង ៥) តើអ្នកណាត្រូវផ្ដល់ជំនួយទ្រទ្រង់ ដល់ការកសាងសមត្ថភាពដ៏ចាំបាច់នានា។

## ការតាំងចិត្តធ្វើការពិសោធន៍សាកល្បង និងរៀនសូត្រតទៅអនាគត

អ្នកចូលរួមក្នុងវេទិកាសិក្ខាសាលាពិគ្រោះយោបល់ ពីកំណែទម្រង់វិស័យជលផល ក្នុងតំបន់បឹងទន្លេសាប កាលពីខែធ្នូ ឆ្នាំ ២០១២ បានឆ្លុះបញ្ចាំងពីសារៈសំខាន់ នៃការចូលរួមពីថ្នាក់មូលដ្ឋានក្នុងការបង្កើតច្បាប់និងគោលនយោបាយផ្សេងៗ ដែលពាក់ព័ន្ធដល់សហគមន៍នេសាទ។ អ្នកចូលរួមយល់ថា ក្របខ័ណ្ឌច្បាប់ផ្សេងៗ ដែលបង្កើតឡើងដោយមិនមានការពិគ្រោះយោបល់ជាមួយសហគមន៍នេសាទ វាអាចមិនសមស្រប និងមិនឆ្លើយតប


តទៅទំព័រ ១៤

# តួនាទីវិនិយោគផ្ទាល់ពីបរទេស ក្នុងការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា[១]

## សេចក្តីផ្តើម

សេដ្ឋកិច្ចកម្ពុជាបន្តកើនឡើងយ៉ាងលឿន ចាប់តាំងពីបានបើកទ្វារទាក់ទងជាមួយសេដ្ឋកិច្ចសាកល នៅពាក់កណ្តាលទសវត្សរ៍ ១៩៩០ មក។ វិស័យកសិកម្មបន្តរួមចំណែកយ៉ាងច្រើនដល់ទៅ ៣៨% នៃ ផសស សរុប ពីឆ្នាំ ១៩៩៥ ដល់ ២០១០ ខណៈដែលវិស័យឧស្សាហកម្មរួមចំណែកបានជិតដល់ ២៣%។ ទោះបីមានកំណើនគួរឲ្យពេញចិត្តដល់ទៅ ១៦% ក្នុងរយៈពេល ១៨ឆ្នាំចុងក្រោយនេះក្តី ក៏ការអភិវឌ្ឍក្នុងវិស័យឧស្សាហកម្ម ត្រូវរាំងស្ទះខ្លះដោយសារចំណូល និងប្រាក់សន្សំក្នុងស្រុកមានកម្រិតទាប និងហេដ្ឋារចនាសម្ព័ន្ធនៅខ្វះខាត។ វិនិយោគផ្ទាល់ពីបរទេស (FDI) ដើរតួនាទីសំខាន់បំផុត ក្នុងការកៀងគរលំហូរមូលធនចូលមកក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងកំពុងមានកំហិតផ្នែកឥណទាន។ វាក៏នាំមកដែរនូវបច្ចេកវិទ្យាថ្មី ជួយជំរុញការអនុវត្តបែបថ្មី ជួយផ្ទេរចំណេះដឹងនិងជំនាញ និងកសាងសមត្ថភាពក្នុងស្រុក។ FDI ជះឥទ្ធិពលខ្លាំងណាស់ជួយលើកកម្ពស់អត្ថប្រយោជន៍ បានពីការធ្វើសមាហរណកម្មក្នុងតំបន់ និងក្នុងសហគមន៍អន្តរជាតិ (Olayiwola and Okodua n.d)។ លក្ខណៈសំខាន់មួយនៃ FDI គឺសមត្ថភាពជួយបង្កើនធនធានមនុស្ស និងបច្ចេកវិទ្យា ដែលជាកត្តាសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចរយៈពេលវែងក្នុងប្រទេសគោលដៅ។ FDI ចាំបាច់ណាស់ ប៉ុន្តែកត្តាតែមួយនេះមិនទាន់គ្រប់គ្រាន់សម្រាប់បង្កកំណើនសេដ្ឋកិច្ចទេ។ ឥទ្ធិពលមានខ្លាំងឬខ្សោយអាស្រ័យលើប្រភពនៃលំហូរ FDI វិស័យដែលបានទទួលវា ចំនួននៃធនធានមនុស្ស (ជំនាញ) ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងសមត្ថភាពស្រូបយករបស់ប្រទេសគោលដៅ។ បទពិសោធន៍សាកលបង្ហាញថា FDI មានដំណើរការល្អក្នុងប្រទេសមានចំណូលខ្ពស់ៗ និងប្រទេសមានគំលាតតូចផ្នែកបច្ចេកវិទ្យា។

អត្ថបទនេះផ្អែកលើលទ្ធផលនៃការសិក្សាមួយ (Phann 2013) ស្តីពី ការរួមចំណែកនៃលំហូរចូល FDI នៅក្នុងផលិតកម្មនៃឧស្សាហកម្មជ្រើសរើសចំនួន ៨ និងវិស័យឧស្សាហកម្មទាំងមូល។ ការសិក្សាបានប្រើ ទិន្នន័យម៉ាក្រូតាមពេលវេលាជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៩៧ ដល់ ២០១០ ដែលទទួលបានពី វិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (UNCTAD)។ មុខងារផលិតកម្ម (Production function) ត្រូវបានយកមកអនុវត្តផ្អែកលើម៉ូដែលកំណើន Solow (Barro and Sala-i-Martin 2004) ដែលគិតបញ្ចូលធាតុចូលតែ២គឺ ចំនួនមូលធន (K) និងពលកម្ម (L) ។ ដើម្បីបញ្ជាក់លើលទ្ធផល ការសិក្សាក៏បានពិនិត្យត្រួសៗពី បទពិសោធន៍នៅប្រទេសថៃ វៀតណាម ហ្វីលីពីន បង់ក្លាដេស និង មីយ៉ាន់ម៉ា ដែរ។

## វិស័យឧស្សាហកម្មកម្ពុជា

ដោយមានការជំរុញឡើងនៅដើមទសវត្សរ៍១៩៩០ ប្រទេសកម្ពុជាមានកំណើនក្នុងវិស័យឧស្សាហកម្មយ៉ាងខ្លាំង រហូតមកដល់ចុងឆ្នាំ២០០៨ ទើបធ្លាក់ចុះបន្តិចដោយសារវិបត្តិហិរញ្ញវត្ថុសាកល ហើយក្រោយមកក៏បានរើបឡើងវិញលឿនគួរសម ប៉ុន្តែមិនទាន់ដល់កម្រិតមុនពេលមានវិបត្តិទេ។ កំណើននេះកើតមានជាសំខាន់ពីវិស័យកាត់ដេរ ដែលជំរុញឡើងជាចម្បងដោយសារវិនិយោគបរទេស ជាពិសេសមកពីប្រទេសចិន។ នាពេលថ្មីៗ ក្នុងផ្នែកកម្មន្តសាលកម្មនៅតាមប្រទេសជឿនលឿន មានការបែកខ្ញែក ដោយសារអាជីវកម្មនានាបានផ្លាស់ប្តូរទីតាំងផលិតកម្មប្រើ

[១] អត្ថបទនេះរៀបរៀងដោយ ផាន់ ដាលីស អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១៖ ចំណែកនៃវិស័យឧស្សាហកម្មផ្សេងៗ នៅក្នុងផលិតកម្មឧស្សាហកម្មសរុប ឆ្នាំ២០០០-២០១០

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2000-2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង | 42.1 | 48.7 | 50.4 | 52.6 | 56.3 | 54.5 | 55.5 | 56.3 | 55.3 | 51.4 | 58.1 | 53.2 |
| សំណង់ | 23.8 | 21.0 | 22.8 | 22.6 | 21.9 | 23.7 | 24.1 | 23.7 | 24.1 | 25.9 | 18.4 | 23.1 |
| អាហារ ភេសជ្ជៈ និងថ្នាំជក់ | 14.6 | 13.5 | 11.2 | 10.5 | 8.5 | 8.2 | 7.2 | 6.8 | 7.0 | 7.5 | 7.7 | 9.4 |
| កម្មន្តសាលកម្មផ្សេងទៀត | 10.0 | 9.0 | 8.4 | 8.1 | 7.5 | 7.8 | 7.6 | 7.5 | 7.7 | 8.5 | 8.6 | 8.3 |
| អគ្គិសនី ឧស្ម័ន និងទឹក | 1.9 | 2.0 | 1.9 | 1.8 | 1.7 | 1.7 | 1.9 | 2.0 | 2.1 | 2.3 | 2.4 | 2.0 |
| ឈើ ក្រដាស និងការបោះពុម្ពផ្សាយ | 4.3 | 2.7 | 2.3 | 1.8 | 1.6 | 1.6 | 1.4 | 1.4 | 1.4 | 1.5 | 1.5 | 2.0 |
| ការជីករ៉ែ | 1.1 | 1.1 | 1.2 | 1.2 | 1.3 | 1.5 | 1.4 | 1.4 | 1.6 | 2.0 | 2.4 | 1.5 |
| ផលិតផលធ្វើពីកៅស៊ូ | 2.2 | 2.0 | 1.7 | 1.4 | 1.1 | 0.9 | 0.8 | 0.8 | 0.8 | 0.9 | 1.0 | 1.2 |

ប្រភព៖ NIS (unpublished data 2000-2010)

តារាង២៖ តួលេខបូកបង្គរនៃការអនុម័តគម្រោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់របស់បរទេស ក្នុងវិស័យឧស្សាហកម្ម ដោយបែងចែកតាមអនុវិស័យ និងប្រទេសប្រភពវិនិយោគ ឆ្នាំ១៩៩៥-២០១០

| ប្រទេស ១៥ ចម្បងគេ (លានដុល្លារ) | វាយនភ័ណ្ឌ សម្លៀកបំពាក់ និង ស្បែកជើង | ការជីករ៉ែ | ឈើ ក្រដាស និង ការបោះពុម្ពផ្សាយ | អាហារ ភេសជ្ជៈ និងថ្នាំជក់ | សំណង់ | ផលិតផល ធ្វើពីកៅស៊ូ | អគ្គិសនី ឧស្ម័ន និងទឹក | កម្មន្តសាលកម្ម ផ្សេងទៀត | 1995-2010 |
|---|---|---|---|---|---|---|---|---|---|
| ចិន | 450.5 | 574.5 | 84.0 | 130.0 | 6.1 | 196.1 | 1211.7 | 305.7 | 2958.6 |
| តៃវ៉ាន់ | 350.7 | 10.0 | 97.3 | 89.9 | 4.2 | | 50.0 | 65.0 | 667.1 |
| កូរ៉េ | 116.0 | 4.3 | 25.8 | 17.2 | 172.5 | 79.0 | 3.2 | 94.8 | 512.8 |
| ថៃ | 16.5 | 2.5 | 22.1 | 365.4 | 46.5 | | 25.4 | 18.0 | 496.4 |
| ម៉ាឡេស៊ី | 63.1 | | 236.2 | 27.6 | 2.7 | 31.7 | 64.8 | 59.0 | 485.1 |
| វៀតណាម | 1.6 | 0.4 | | 25.1 | 3.3 | 276.8 | 2.8 | 74.7 | 384.7 |
| សិង្ហបុរី | 57.2 | | 11.0 | 79.1 | 1.6 | 41.4 | 16.5 | 12.6 | 219.4 |
| ហុងកុង | 108.0 | | 62.5 | 10.1 | 4.3 | | | 25.3 | 210.2 |
| សហរដ្ឋអាមេរិក | 34.3 | 1.3 | 20.4 | 1.4 | | 28.5 | 8.7 | 53.4 | 148.0 |
| កាណាដា | 20.5 | 2.5 | | 4.3 | 39.5 | | | 13.7 | 80.5 |
| អង់គ្លេស | 68.4 | | 0.1 | 13.5 | | | | 2.3 | 84.3 |
| ឥណ្ឌា | | | | | | | 75.0 | 0.3 | 75.3 |
| ជប៉ុន | 7.1 | | | 31.5 | 2.8 | | | 15.2 | 56.6 |
| អូស្ត្រាលី | 12.9 | 4.3 | 5.3 | 15.8 | | | 0.3 | 2.3 | 40.9 |
| បែលហ្សិក | | | | | | | | 35.0 | 35.0 |
| សរុប | 1337.9 | 605.0 | 604.4 | 825.9 | 290.2 | 653.5 | 1459.3 | 794.6 | 6570.8 |

ប្រភព៖ CDC ( unpublished data 1995-2010 )

ពលកម្មច្រើន ទៅកាន់ប្រទេសមានតម្លៃពលកម្មថោកជាង ដើម្បីរក្សាលក្ខណៈប្រកួតប្រជែងរបស់ខ្លួន។ ព្រឹត្តិការណ៍នេះ ទំនងបើកផ្លូវមួយឲ្យកម្ពុជាបង្កើនគុណភាព និងធ្វើពិពិធកម្មរចនាសម្ព័ន្ធឧស្សាហកម្មរបស់ខ្លួន (Kimura 2009 cited in Banomyong 2010)។ វិស័យឧស្សាហកម្មកម្ពុជាបានល្អប្រសើរឡើងក៏ពិតមែន ប៉ុន្តែវាបានរីកលូតលាស់ដោយផ្អែកលើឧស្សហកម្មធុំដំឡើងដែលប្រើបច្ចេកទេសទាប និងប្រើពលកម្មច្រើន។ ឧស្សាហកម្មចម្បងៗនៅកម្ពុជា រួមមាន ការជីករ៉ែ, ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង, ឈើ ក្រដាស និងការបោះពុម្ពផ្សាយ, ផលិតផលធ្វើពីកៅស៊ូ, អគ្គិសនី ឧស្ម័ន និងទឹក, សំណង់ និងកម្មន្តសាលកម្មផ្សេងៗទៀត (តារាង១)។

## លំហូរចូល FDI ក្នុងឧស្សាហកម្មនៅកម្ពុជា

អត្រាសន្សំក្នុងប្រទេសកម្ពុជា មានកម្រិតទាប ត្រឹម ១៦% នៃ ផសស ពីឆ្នាំ២០០០ ដល់ ២០១០ ដែលបង្កនូវកង្វះទុនវិនិយោគក្នុងស្រុក និងតម្រូវការទាក់ទាញ FDI។ ក្រៅពីការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ, FDI ក៏នាំមកនូវទ្រព្យផលិតកម្មផ្សេងៗ និងចំណេះដឹងដែលអាចជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ នៅកម្ពុជា លំហូរចូល FDI តែងកំណត់ឡើងដោយកត្តាខាងក្រៅ (ដូចជា វិបត្តិក្នុងប្រទេសប្រភព FDI, លក្ខខណ្ឌអំណោយផលក្នុងទីផ្សារអន្តរជាតិ) ជាជាង កត្តាក្នុងស្រុក ដូចជា ពលកម្មថោក និងធនធានវត្ថុធាតុដើម ជាដើម។ ក្នុងឆ្នាំ២០១០ លំហូរចូល FDI មកក្នុងប្រទេសកម្ពុជា កើនដល់ ៥,៣% នៃ ផសស ធៀបនឹង ៣.៨% ក្នុងទសវត្សរ៍១៩៩០ និងត្រឹម ០,០២% ក្នុងទសវត្សរ៍១៩៧០ (UNCTAD)។ គិតជាមធ្យម ក្នុងឆ្នាំ២០០០-២០១០ វិស័យសេវាកម្មទទួលបានលំហូរចូល FDI ច្រើនបំផុត ដល់ទៅ ៥០% នៃ FDI សរុប ដែលបានអនុម័ត ហើយវិស័យឧស្សាហកម្មទទួលបាន ៤៩%។

រហូតមកទល់បច្ចុប្បន្ន ក្រៅពីសិទ្ធិពិសេសដែលផ្តល់ទៅឲ្យផ្នែកវាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង គឺនៅមិនទាន់មានកត្តាស្នូលអ្វីដែលចងភ្ជាប់វិនិយោគបរទេស ជាមួយនឹងសកម្មភាពឧស្សាហកម្មដទៃទៀតនៅកម្ពុជាឡើយ។ ទោះបីកម្ពុជាមានលក្ខណៈទាក់ទាញ ដោយសារសម្បូរកម្លាំងពលកម្មមានតម្លៃទាបក្តី ប៉ុន្តែ បន្ទុកចំណាយដ៏ខ្ពស់ក្នុងការបើកដំណើរការ និងធ្វើអាជីវកម្ម បានបន្ទុចបង្អាក់ដល់ FDI។ រូបភាព ១ ដែលប្រើសូចនាករនៃការធ្វើអាជីវកម្ម និងចងក្រងឡើងដោយធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បង្ហាញនូវចំណាត់ថ្នាក់ប្រទេសកម្ពុជា ក្នុងចំណោម ១៨៣ប្រទេស។

រូបភាព ១ ៖ ចំណាត់ថ្នាក់ការធ្វើអាជីវកម្មនៅកម្ពុជា ឆ្នាំ២០១២




ប្រភព៖ World Bank and IFC (2012), ការធ្វើអាជីវកម្ម

## ឥទ្ធិពល FDI នៅលើវិស័យឧស្សាហកម្ម: ក្របខ័ណ្ឌវិភាគផ្អែកលើបទពិសោធន៍ជាក់ស្ដែង

ការសិក្សានេះ វិភាគពីការរួមចំណែកនៃ FDI ក្នុងការអភិវឌ្ឍឧស្សាហកម្ម ដោយប្រើជាមុខងារផលិតកម្ម Cobb-Douglas production function (Barro and Sala-i-Martin 2004) ដែលបង្ហាញពីការប្រែប្រួលនៃផលិតផលសម្រេច ដោយសារមូលធន និងពលកម្ម ដែលដាក់ចូលទៅក្នុងដំណើរការផលិតកម្ម។ អ្នកស្រាវជ្រាវបានដាក់អនុវត្ត មុខងារផលិតកម្មខាងក្រោម សម្រាប់វិស័យឧស្សាហកម្មផ្សេងៗ សម្គាល់ឡើងដោយ i នៅកាល t ។

$$Y=F(K, L) \quad (1)$$

where Y is real output of each industrial sector, K is physical capital and L is labour. K is defined by the sum of domestic capital stock ($K_d$) and foreign capital stock ($K_f$), which can be written as $K_{total}= K_d+ K_f$. The regression equation then assumes the following linear form:

$$logGDP_{it}=b_{oi}+b_{ii}logK_{dii(t-1)}+b_{2i}logK_{fi(t-1)}+b_{2i}logK_{fi(t-1)}+b_{3i}logL_{it}+u_{it} \quad (2)$$

where $GDP_{it}$= the outputs of each industrial sector i at time t; $b_{0i}$, $b_{1i}$, $b_{2i}$ and $b_{3i}$ are the intercept terms and coefficients of each variable; $u_{it}$ is a term of residual of i sectors (i=1, 2, 3... 9 representing the eight selected industrial sub-sectors and the overall industrial sector); $K_{di}$ = DomK and $K_{fi}$ = FDIK which denote domestic and foreign capital stocks of industrial i.

To allow for delayed returns to capital outlay, as it may take enterprises some time to order and install capital assets such as machinery and equipment prior to operating, the study takes one lag of $K_{di}$ and $K_{fi}$ calculated using the perpetual inventory method. Then, $K_{(t+1)} = (1-d) * K_t + I_{(t+1)}$ where $K_{(t+1)}$ and $K_t$ are the capital stock in time (t+1); t. d is the depreciation rate of capital, which is set at 5.0 percent for Cambodia (see Net 2011); and $I_{t+1}$ is the fixed assets investment inflow at time (t+1). The fixed assets investment shared by Cambodia is represented by $I_{d(t+1)}$, while the share of foreign nationality is written as $I_{f(t+1)}$. This study takes $K_{1995}$ as the initial capital stock for both domestic and foreign capital stocks for each selected industrial sector. Based on the assumption that the rate of capital-output ratio was constant during the 1990s, it then calculates $K_{1995} = I_{1995}/(g_{1990s}+d)$ following Harberger (1978), where $g_{1990s}$ is the average growth rate of capital, which is equal to the growth rate of outputs (GDP) during the 1990s, and $L_i$ is employment in sector i.

## លទ្ធផល

ការប៉ាន់ស្មានតាមសេដ្ឋកិច្ចមាត្រសាស្ត្របង្ហាញថា FDI មានផលល្អទៅលើឧស្សាហកម្មបួនវិស័យ គឺមាន អាហារ ភេសជ្ជៈ និងថ្នាំជក់, វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង, ទឹក និង

$$logGDP_food_t = b_{0food} + b_{1food}logDomK_food_{t-1} + b_{2food}logFDIK_food_{t-1} + b_{3food}logLabor_food_t + u_{foodt} \quad (2.1)$$

$$logGDP_textiles_t = b_{0textiles} + b_{1textiles}logDomK_textiles_{t-1} + b_{2textiles}logFDIK_textiles_{t-1} + b_{3textiles}logLabor_textiles_t + u_{textilest} \quad (2.2)$$

$$logGDP_rubber_t = b_{0rubber} + b_{1rubber}logDomK_rubber_{t-1} + b_{2rubber}logFDIK_rubber_{t-1} + b_{3rubber}logLabor_rubber_t + u_{rubbert} \quad (2.3)$$

$$logGDP_mining_t = b_{0mining} + b_{1mining}logDomK_mining_{t-1} + b_{2mining}logFDIK_mining_{t-1} + b_{3mining}logLabor_mining_t + u_{miningt} \quad (2.4)$$

$$logGDP_utility_t = b_{0utility} + b_{1utility}logDomK_utility_{t-1} + b_{2utility}logFDIK_utility_{t-1} + b_{3utility}logLabor_utility_t + u_{utilityt} \quad (2.5)$$

$$logGDP_wood_t = b_{0wood} + b_{1wood}logDomK_wood_{t-1} + b_{2wood}logFDIK_wood_{t-1} + b_{3wood}logLabor_wood_t + u_{woodt} \quad (2.6)$$

$$logGDP_construc_t = b_{0construc} + b_{1construc}logDomK_construc_{t-1} + b_{2construc}logFDIK_construc_{t-1} + b_{3construc}logLabor_construc_t + u_{construct} \quad (2.7)$$

$$logGDP_othermanu_t = b_{0othermanu} + b_{1othermanu}logDomK_othermanu_{t-1} + b_{2othermanu}logFDIK_othermanu_{t-1} + b_{3othermanu}logLabor_othermanu_t + u_{othermanut} \quad (2.8)$$

$$logGDP_indus_t = b_{0indus} + b_{1indus}logDomK_indus_{t-1} + b_{2indus}logFDIK_indus_{t-1} + b_{3indus}logLabor_indus_t + u_{indust} \quad (2.9)$$

តារាង ៣: Ordinary Least Squares Results of Equation (2)

| Dependent variable: LogGDP(t)_i<br>Method: Ordinary Least Squares<br>Sample: 1997, 2010<br>Included observations: 14 | | | | |
|---|---|---|---|---|
| | Constant | Coef. logDomK (t-1)_i | Coef. logFDIK (t-1)_i | Coef. logLabor(t)_i |
| (2.1) logGDP(t)_food | 4.415*** | -0.045 | 0.192*** | -0.023 |
| (2.2) logGDP(t)_textiles | 2.330** | -0.557 | 1.612** | -0.213 |
| (2.3) logGDP(t)_rubber | 3.113*** | -0.002 | 0.038 | -0.049 |
| (2.4) logGDP(t)_mining | -0.629 | 0.291 | 0.019 | 0.319*** |
| (2.5) logGDP(t)_utilities | 2.291*** | 0.164*** | 0.205** | -0.035 |
| (2.6) logGDP(t)_wood | 6.537*** | -0.330 | -0.014 | -0.194** |
| (2.7) logGDP(t)_construc | 0.253 | 0.594** | -0.345 | 0.330*** |
| (2.8) logGDP(t)_othermanu | 2.973*** | -0.079 | 0.493*** | -0.025 |
| (2.9) logGDP(t)_indus | 0.138 | 1.542** | -0.600 | 0.137 |

Note: * 10 percent, ** 5 percent and *** 1 percent level of significance. Source: Author’s calculation.

អគ្គិសនី, និងកម្មន្តសាលកម្មផ្សេងទៀត។ ទោះយ៉ាងនេះក្ដី FDI កំពុងស្ថិតក្នុងដំណាក់កាល មានផលត្រឡប់ថយចុះជាលំដាប់ (តារាង ៣) ដែលបង្ហាញពីការប្រើប្រាស់មូលធនមិនមានប្រសិទ្ធភាព ហើយត្រូវការកែលំអផលិតភាព។ កម្ពុជានៅមិនទាន់ឈានឡើងដល់កម្រិតអាចយកចំណេញ បានពីសេដ្ឋកិច្ចមាត្រដ្ឋាននោះទេ។ ការសិក្សាមិនអាចបញ្ជាក់ពីឥទ្ធិពលនៃ FDI លើឧស្សាហកម្មទាំងមូលបាននោះទេ។ ឥទ្ធិពលខុសៗគ្នានៃ FDI ទៅលើវិស័យឧស្សាហកម្មខុសៗគ្នា អាចបណ្ដាលមកពីលក្ខណៈនៃ FDI ខ្លួនឯង, លក្ខណៈសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យជាក់លាក់នីមួយៗ, របាំងផ្សេងៗក្នុងបទបញ្ញត្តិច្បាប់, និងការិយាល័យធិបតេយ្យ (Lean, 2008)។ គេរកឃើញថា ម៉ូដែលទាំងអស់ហាក់ដូចជាប់ពាក់ព័ន្ធខ្លាំងទៅនឹងអថេរពេលវេលា គឺបានន័យថា ពេលវេលាមានផលប៉ះពាល់ ខ្លាំងជាង លក្ខណៈនៃទិន្នន័យ។ ដូច្នេះក្នុងរយៈពេលខ្លី ទិន្នន័យគុណភាពអន់និងមិនសូវច្បាស់លាស់ អាចធ្វើឲ្យលទ្ធផលរកឃើញមិនអាចប្រើការបាន ។

## បទពិសោធន៍បានពីប្រទេសជ្រើសរើសមួយចំនួនសម្រាប់កម្ពុជា

រចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា វាស្រដៀងគ្នានឹងនៅវៀតណាម បង់ក្លាដេស និង មីយ៉ាន់ម៉ា ដែរ។ វិស័យឈានមុខគេនៅតែជា វាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង និងបន្ទាប់មកទៀត ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ដែលអំណោយផលល្អ ដោយសារមានកម្លាំងពលកម្មច្រើន និងតម្លៃទាប។ ផលិតកម្មវាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង ពឹងផ្អែកជាខ្លាំងលើការនាំចូល និងផ្គុំដំឡើង ធាតុចូលអន្តរការី (ផលិតផលពាក់កណ្ដាលសម្រេច) ដែលមានន័យថានៅពេលកាលៈទេសៈប្រែប្រួលអាក្រក់ ឬក៏ផុតកំណត់លក្ខខណ្ឌអនុគ្រោះ វិនិយោគក្នុងវិស័យនេះអាចរត់ចេញពីកម្ពុជាយ៉ាងលឿន។ ចំណុចផ្ដោតមួយក្នុងគោលនយោបាយរដ្ឋាភិបាល គឺការធ្វើពិពិធកម្មអនុវិស័យកែច្នៃម្ហូបអាហារ ដែលនៅក្មេងខ្ចីដោយសារមានផលិតផលតិចមុខ និងស្ដង់ដារគុណភាពអន់។

ដោយសារកម្ពុជា មិនទាន់មានលទ្ធភាពធ្វើវិនិយោគផ្នែកឧស្សាហកម្មធុនធ្ងន់ និងបច្ចេកវិទ្យាខ្ពស់ៗ ក្នុងពេលដ៏ខ្លីបាន ដូច្នេះត្រូវតែបន្តទ្រទ្រង់ឧស្សាហកម្មសព្វថ្ងៃ ដែលប្រើពលកម្មច្រើននេះ ហើយគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ក្នុងដំណាក់កាលបច្ចុប្បន្ន គួរលើកកម្ពស់ចំណងទាក់ទងគ្នាក្នុងកសិកម្ម និងផលិតកម្មប្រើពលកម្មច្រើន។ ចំណុចនេះសំខាន់ណាស់ ប្រសិនបើកម្ពុជាចង់សម្រេចបានសេដ្ឋកិច្ចមាត្រដ្ឋាន និងការអភិវឌ្ឍឧស្សាហកម្មប្រើបច្ចេកវិទ្យាខ្ពស់ ដែលនឹងជួយឲ្យកម្ពុជាអាចពង្រីកធនធានមនុស្ស មូលធនរូបវន្ត និងបង្កើនផលិតភាព ដើម្បីឲ្យដំណើរការឧស្សាហភាវូបនីយកម្មមានចីរភាព និងលក្ខណៈធន់ទ្រាំល្អ។ កម្ពុជាក៏ត្រូវរៀនជ្រើសរើសប្រភពវិនិយោគឲ្យបានល្អ ដើម្បីកសាងកម្លាំងប្រកួតប្រជែងរបស់ខ្លួន ជំរុញការអនុវត្តបែបថ្មី និងកាត់បន្ថយភាពក្រីក្រ។

## ការសន្និដ្ឋាន

លទ្ធផលសិក្សាតាមសេដ្ឋកិច្ចមាត្រសាស្ត្រ និងការវិភាគករណីសិក្សា បង្ហាញថា មានអនុវិស័យពីរដែលទំនងទាក់ទាញវិនិយោគខ្លាំង ពោលគឺ ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, ហើយនិងវាយនភ័ណ្ឌ សម្លៀកបំពាក់ និងស្បែកជើង។ កម្ពុជាក៏ត្រូវរៀបចំខ្លួនដើម្បីទាក់ទាញគម្រោងវិនិយោគ មានប្រើបច្ចេកវិទ្យាខ្ពស់ៗ ដើម្បីអាចប្រកួតប្រជែងបានជាមួយគូប្រជែងថ្មីៗ ដូចជា មីយ៉ាន់ម៉ាជាដើម និងត្រៀមដោះស្រាយបញ្ហាថ្លៃឈ្នួលពលកម្មខ្ពស់ដែលអាចកើតមាននាពេលអនាគត។ក្នុងជំហានទី១កម្ពុជាគួរកំណត់នូវអនុវិស័យឧស្សាហកម្ម និងតំបន់ដ៏មានសក្ដានុពលនានា ហើយផ្ដល់អាទិភាពឲ្យ នៅក្នុងយុទ្ធសាស្ត្រគោលនយោបាយរបស់ខ្លួន។ ម្យ៉ាងទៀត កម្ពុជាក៏ត្រូវរៀនពីរបៀបបង្កើត និងគ្រប់គ្រងលក្ខខណ្ឌចាំបាច់ត្រូវមានជាមុននានា ដើម្បីពង្រឹងវិស័យផ្សេងៗដែលសម្រាប់ជួយទ្រទ្រង់ដល់ឧស្សាហកម្ម។ជម្រើសគោលនយោបាយផ្សេងៗយ៉ាងត្រឹមត្រូវ ពិតជាសំខាន់បំផុតសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ជាពិសេសក្នុងពេលធនធានផលិតកម្មនៅមានតិចបែបនេះ៕



ឯកសារយោងមាននៅក្នុងអត្ថបទជាអង់គ្លេស

# ករណីសិក្សាៈ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវនៅខេត្តតាកែវ[1]

## សេចក្តីផ្តើម

នៅអំឡុងឆ្នាំ២០០១-១០ ផលិតកម្មកសិកម្មបានកើនឡើងគួរឲ្យកត់សម្គាល់ ដោយមានអត្រាកំណើនជាមធ្យមប្រហែល ៥%។ ស្រូវជាអនុវិស័យដំណាំធំជាងគេ ដោយមានកំណើនជាមធ្យម ៧,៧% ក្នុងមួយឆ្នាំ និងរួមចំណែក ២៦% ក្នុងផលិតផលក្នុងស្រុកសរុប (ផសស) ខាងកសិកម្ម (NIS 2011)។ ទោះមានការរីកចម្រើនបែបនេះក្តី ការសិក្សាជាច្រើនបានពិនិត្យឃើញនូវឧបសគ្គក្រោយការប្រមូលផលផ្សេងៗ ដែលជះឥទ្ធិពលទៅលើផលិតភាពវិស័យកសិកម្ម មានជាអាទិ៍ ១) ការខាតបង់កម្រិតខ្ពស់ និងគុណភាពអន់ ដោយសាររបៀបទុកដាក់ផលស្រូវ កន្លែងស្តុកផលស្រូវ ហើយនិង ស្តង់ដារ និងសមត្ថភាពកិនស្រូវ ២) បន្ទុកចំណាយផលិតកម្មខ្ពស់ គួបផ្សំនឹងទិន្នផលទាបក្នុងឆ្នាំខ្លះ ៣) ស្តង់ដារ និងលក្ខណៈក្រៅផ្លូវការនៃពាណិជ្ជកម្មឆ្លងកាត់ព្រំដែនជាមួយថៃ និង វៀតណាម (ACI and CamConsult 2006; RGC 2010; Sok *et al.* 2011)។ ក្តីបារម្ភដ៏ធំសម្រាប់កសិករដាំស្រូវ គឺបន្ទុកចំណាយផលិតកម្មខ្ពស់ ហើយនិងការសម្របសម្រួល និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារអន់ខ្សោយ។

ខេត្តតាកែវមានសក្តានុពលធំធេង ខាងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន។ ការលក់ស្រូវទៅឲ្យប្រទេសវៀតណាម បានក្លាយជាលក្ខខណ្ឌដ៏សំខាន់បំផុតមួយ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងខេត្ត។ ការសិក្សាពីចំណាយផលិតកម្ម និងខ្សែចង្វាក់តម្លៃទីផ្សារក្នុងខេត្ត អាចជួយបំភ្លឺពីបែបបទនៃការបែងចែកអត្ថប្រយោជន៍ផ្សេងៗក្នុងចំណោមតួអង្គស្ថិតក្នុងខ្សែចង្វាក់នៃតម្លៃ និងពីឧបសគ្គក្រោយការច្រូតកាត់នានា ដែលរារាំងដល់ការអភិវឌ្ឍវិស័យស្រូវនៅកម្ពុជា។ ការសិក្សានេះមានគោលដៅពិនិត្យពីខ្សែចង្វាក់តម្លៃទីផ្សារស្រូវនៅខេត្តតាកែវ និងផ្តល់មតិពីជម្រើសគោលនយោបាយដើម្បីបង្កើន អត្ថប្រយោជន៍ដែលអ្នកដាំស្រូវត្រូវទទួលបាន និងតម្លៃបន្ថែមនៃដំណាំស្រូវនៅកម្ពុជា។ គោលដៅដ៏ជាក់លាក់នានារួមមាន៖ ១) កំណត់ឲ្យច្បាស់នូវខ្សែចង្វាក់តម្លៃនៃដំណាំស្រូវ ២) វិភាគចំណូល ចំណាយ និងអត្រាចំណេញក្នុងផលិតកម្មស្រូវ ៣) ពិនិត្យលើព័ត៌មានទីផ្សារ និងកំណត់ពីទំនាក់ទំនងផ្នែកអភិបាលកិច្ចរវាង សហគ្រាសនានាដែលស្ថិតនៅលំដាប់ជាប់គ្នាក្នុងខ្សែចង្វាក់តម្លៃ និង ៤) កំណត់នូវគោលនយោបាយសមស្របដើម្បីកែលំអការលក់ស្រូវទៅទីផ្សារក្នុងខេត្តតាកែវ។

វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព និងបែបបរិមាណ ដែលអនុវត្តក្នុងការសិក្សាស្តីពី "ការធ្វើឲ្យខ្សែចង្វាក់តម្លៃ កាន់តែអំណោយផលដល់ជនក្រីក្រ" (M4P 2008) ត្រូវបានយកមកប្រើដើម្បី កំណត់នូវ ខ្សែចង្វាក់តម្លៃ និងរចនាសម្ព័ន្ធសម្របសម្រួលសម្រាប់ដំណាំស្រូវ, យន្តការត្រួតពិនិត្យ, ច្បាប់ និងបទបញ្ញត្តិផ្សេងៗដែលអនុវត្តនៅខេត្តតាកែវ។ ការចុះសិក្សាដល់កន្លែងដើម្បីប្រមូលទិន្នន័យ បានធ្វើឡើងចាប់ពីពាក់កណ្តាលខែកុម្ភៈ ដល់ពាក់កណ្តាលខែមីនា ឆ្នាំ២០១២។ ព័ត៌មានសម្រាប់ការសិក្សានេះក៏ទទួលបានផងដែរតាមរយៈ ការសង្កេតពិនិត្យនៅផ្ទាល់កន្លែង ការពិភាក្សាតាមក្រុមស្នូល និងការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ ដែលជាតួអង្គស្ថិតក្នុងខ្សែចង្វាក់តម្លៃ គឺមានតាំងពីកសិករ អ្នកប្រមូលទិញស្រូវ ពាណិជ្ជករ រហូតដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ។ ការពិភាក្សាតាមក្រុមស្នូលជាមួយកសិករ បានធ្វើឡើងនៅតាមភូមិនានាក្នុងស្រុក ត្រាំកក់ ព្រៃកប្បាស និងកោះអណ្តែត។ ព័ត៌មានស្តីពីការលក់ក៏បានប្រមូលយកនៅក្រុងតាកែវ និង ពីរស្រុកថែមទៀត គឺ អង្គរបុរី និងគិរីវង្ស។ ទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ ទាំងបែបបរិមាណ និងបែបគុណភាព បានយកមកប្រើដើម្បីវិភាគពីតម្លៃបន្ថែមរវាងតួអង្គដែលស្ថិតនៅលំដាប់ជាប់គ្នាក្នុងខ្សែចង្វាក់តម្លៃបន្ថែម។

## លទ្ធផល និងការពិភាក្សា

### *ការកំណត់ខ្សែចង្វាក់តម្លៃ*

ខ្សែចង្វាក់តម្លៃស្រូវ មានពីរ គឺរដូវវស្សា និង រដូវប្រាំង។ កសិករភាគច្រើនដាំស្រូវវស្សាជាចម្បង សម្រាប់ការប្រើប្រាស់ក្នុងផ្ទះ។ កសិករមួយចំនួនតូចដែលដាំស្រូវប្រាំង តែងមានគោលបំណងសំខាន់ដើម្បីធ្វើពាណិជ្ជកម្ម។ តួអង្គទាំងអស់ក្នុងខ្សែចង្វាក់តម្លៃស្រូវប្រាំងគឺសកម្មខ្លាំង រីឯតួអង្គក្នុងខ្សែចង្វាក់តម្លៃរដូវវស្សាមិនសូវសកម្មទេ។ អ្នកប្រមូលទិញស្រូវ និងពាណិជ្ជករតាមភូមិ ជាតួអង្គសំខាន់នៅក្នុងខ្សែចង្វាក់តម្លៃទាំងពីរ (រូបភាព ១) និងជាសហគ្រាសធុនតូចដែលមានសមត្ថភាពទិញស្រូវត្រឹម ១០ ទៅ ៣០តោន ដោយសារកង្វះខាតមធ្យោបាយដឹកជញ្ជូន និងដើមទុន។ ពួកគេទិញស្រូវផ្សេងៗមកលាយចូលគ្នា ប៉ុន្តែបែងចែកប្រភេទស្រូវគុណភាពខ្ពស់ ទុកលក់ក្នុងថ្លៃខ្ពស់ទៅឲ្យពាណិជ្ជករក្នុងតំបន់។ ជាទូទៅ អ្នកប្រមូលទិញស្រូវ និងពាណិជ្ជករក្នុងភូមិ គឺជាកសិកររស់នៅក្នុងភូមិដែលប្រើដើមទុនរបស់ពាណិជ្ជករកម្រិតតំបន់ សម្រាប់យកទៅប្រមូលទិញស្រូវពីកសិករដទៃទៀត ហើយផ្គត់ផ្គង់ទៅឲ្យពាណិជ្ជករតំបន់ ដើម្បីយកប្រាក់កម្រៃជើងសារ ០,០៥ដុល្លារ/បាវ៥០គីឡូ ឬប្រើមូលធនផ្ទាល់ខ្លួនដើម្បីទិញ និងលក់ស្រូវយកចំណេញ។

### *ចំណាយផលិតកម្ម អត្រាចំណេញដុល និង ផលត្រឡប់លើចំណាយសុទ្ធគិតក្នុងមួយថ្ងៃពលកម្មម្ចាស់កសិដ្ឋាន[2]*

កសិករដាំស្រូវនៅក្នុងតំបន់សិក្សា ត្រូវប្រឈមមុខនឹងចំណាយខ្ពស់ទៅលើ ការជួលពលករ និងគ្រឿងម៉ាស៊ីន (សម្រាប់ការ

---

[1] រៀបរៀងដោយលោក ឈឹម ឈន់ ជាអ្នកស្រាវជ្រាវ, បណ្ឌិត ថេង វុទ្ធី ជាអ្នកស្រាវជ្រាវ និង លោក នូ កែវសុទ្ធា ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៅ CDRI ។ អត្ថបទនេះផ្អែកលើ ករណីសិក្សាពីខ្សែចង្វាក់តម្លៃបន្ថែមនៃទីផ្សារស្រូវ សម្រាប់គម្រោងទ្រទ្រង់ដោយ ACIAR (ASEM/2009/023) ស្តីពី "ការអភិវឌ្ឍគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅឡាវ និងកម្ពុជា" ដែលគ្រោងចប់រួចរាល់នៅខែឧសភា ២០១៤។

[2] ផលត្រឡប់លើចំណាយសុទ្ធគិតក្នុងមួយថ្ងៃពលកម្មម្ចាស់កសិដ្ឋាន=(ទិន្នផល-ចំណាយផ្សេងៗ និងថ្លៃឈ្នួល(មនុស្ស សត្វ សម្ភារៈ)) / ចំនួនថ្ងៃធ្វើការរបស់ម្ចាស់កសិដ្ឋាន។

រូបភាព ១៖ ផែនទី និង លំដាប់លំដោយនៃតួអង្គក្នុងខ្សែចង្វាក់តម្លៃស្រូវនៅខេត្តតាកែវ




រៀបចំដី), ជី, ថ្នាំសម្លាប់សត្វចង្រៃ (សម្រាប់ស្រូវប្រាំង), គ្រាប់ពូជ, និងទឹកស្រោចស្រព (រូបភាព ២ និង ៣)។ ចំណាយលើពលកម្មមានច្រើនដល់ប្រហែល ៣០% នៃចំណាយផលិតកម្មសរុប ឬ ១៥% នៃតម្លៃផលស្រូវវស្សាប្រមូលបានសរុប (តារាង ១)។ កសិករដាំស្រូវវស្សា ភាគច្រើនដាំដុះតាមបែបប្រពៃណី ដែលត្រូវចំណាយច្រើនបំផុតទៅលើការជួលពលកម្ម ជាពិសេសសម្រាប់ការដកស្ទូងដែលត្រូវប្រើពលកម្មច្រើនជាង បើធៀបនឹងស្រូវពង្រោះដែលសមាជិកគ្រួសារតែងធ្វើការដោយខ្លួនឯង។ រីឯកសិករដាំស្រូវប្រាំងវិញ គាត់ប្រើប្រព័ន្ធដាំដុះអតិផល ដែលក្នុងនោះការដាំស្រូវពង្រោះ និងការប្រើគ្រឿងម៉ាស៊ីន បានកាត់បន្ថយដល់សូន្យនូវចំណាយលើការជួលកម្លាំងពលកម្ម។

ថ្លៃទឹកសម្រាប់ការដាំដុះនៅរដូវវស្សា មានចំណែក ២៥% នៃចំណាយផលិតកម្ម ឬ ១៣% នៃតម្លៃផលស្រូវប្រមូលបាន រីឯថ្លៃទឹកសម្រាប់ការដាំដុះនៅរដូវប្រាំង មានចំណែក ១៩% នៃចំណាយផលិតកម្ម ឬ ១១% នៃតម្លៃផលស្រូវប្រមូលបាន[៣]។ ថ្លៃទឹកប្រើប្រាស់ជាចំណាយខ្ពស់បំផុតមួយដែលកសិករ ជាពិសេសកសិករដាំស្រូវប្រាំង តែងត្អូញត្អែរច្រើនជាងគេ។

កសិករធ្វើស្រែប្រាំងចំណាយធំបំផុតលើ ជីគីមី ដែលមាន

[៣] កសិករដាំស្រូវវស្សាចំណាយលើការប្រើទឹកច្រើនជាងកសិករស្រូវប្រាំង ព្រោះមានការរាំងស្ងួតមួយរយៈពេលខ្លីក្នុងរដូវដាំដុះឆ្នាំ២០១១ ហើយគាត់ត្រូវចំណាយជួលម៉ាស៊ីនបូមទឹក និងទិញប្រេងឥន្ធនៈ ដើម្បីបូមទឹកស្រោចស្រពស្រូវគាត់។

រូបភាព ២៖ ចំណាយដាំដុះនៅរដូវវស្សា (ក្នុងមួយហិកតា)




រូបភាព ៣៖ ចំណាយដាំដុះនៅរដូវប្រាំង (ក្នុងមួយហិកតា)




ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើការធ្វើសម្ភាសន៍ដល់កន្លែង អនុវត្តក្នុងខែឧសភា ២០១២

ចំណែកជាមធ្យម ២៣% នៃចំណូលបានពីផលស្រូវសរុប រីឯកសិករធ្វើស្រែវស្សាចំណាយទិញជីតិចជាងនេះច្រើន ត្រឹមប្រហែល ១១% នៃចំណូលបានពីផលស្រូវសរុប (តារាង ១)។ ចំពោះបរិមាណជីប្រើប្រាស់វិញ កសិករប្រាប់ថា គាត់អនុវត្តតាមការណែនាំរបស់អ្នកលក់ជី ឬអ្នកជិតខាង។ កសិករឯទៀត ជាពិសេសអ្នកធ្វើស្រែប្រាំងបានប្រាប់ថា គាត់ដាក់ជីទៅតាមលទ្ធភាពអាចធ្វើបាន ដើម្បីទទួលបានទិន្នផលខ្ពស់។

ការទិញថ្នាំសម្លាប់សត្វចង្រៃជាចំណាយធំមួយទៀត ជាពិសេសសម្រាប់កសិករធ្វើស្រែប្រាំង។ ជាទូទៅ កសិករធ្វើស្រែវស្សាមិនប្រើថ្នាំសម្លាប់សត្វចង្រៃទេ លើកលែងតែមានសត្វចង្រៃរាតត្បាតខ្លាំងពេក។

កសិករធ្វើស្រែវស្សាតែងទុកស្រូវបានពីស្រែរបស់ខ្លួនសម្រាប់ធ្វើពូជ ហើយចូលចិត្តប្រើស្រូវពូជរបស់ខ្លួនឯង ព្រោះគាត់មានលទ្ធភាពតែប៉ុណ្ណេះ។ ប៉ុន្តែកសិករធ្វើស្រែប្រាំងតែងទិញគ្រាប់ពូជមានថ្លៃខ្ពស់គួរសម ប្រហែលជា ៦% នៃតម្លៃផលស្រូវប្រមូលបាន (តារាង ១)។

ជាមធ្យម ស្រូវវស្សាផ្តល់ទិន្នផល ២,៣តោន/ហិកតា ហើយស្រូវប្រាំងផ្តល់ប្រហែល ៧,២តោន/ហិកតា។ ថ្លៃលក់ស្រូវនៅកន្លែងកសិដ្ឋាន គឺប្រហែល ២៥០ដុល្លារ/តោន សម្រាប់ស្រូវវស្សា និង ១៩៤ដុល្លារ/តោន សម្រាប់ស្រូវប្រាំង។ ថ្លៃលក់ស្រូវវស្សានៅតាមកសិដ្ឋានស្រង់បានពីការចុះសម្ភាសដល់កន្លែងកាលពីខែមីនា ២០១២ វាស្រដៀងគ្នានឹងថ្លៃស្រង់បានសម្រាប់ខែតុលា ២០១១ដែរ (RGC 2011)។ ចំណូលដុលបានពីកសិដ្ឋានជាមធ្យម គឺ ៥៧៥ដុល្លារ សម្រាប់ស្រូវវស្សា និង ១៣៩៦ដុល្លារ សម្រាប់ស្រូវប្រាំង (តារាង ១)។ ចំណាយផលិតកម្មទាំងសម្រាប់ស្រូវវស្សា និងស្រូវប្រាំង វាខ្ពស់ជាខ្លាំង ហើយភាគច្រើនស្ថិតនៅក្រៅលទ្ធភាពគ្រប់គ្រងរបស់កសិករ ដែលធ្វើឲ្យប្រាក់ចំណេញដុលមានកម្រិតទាបសម្រាប់ផលិតកម្មស្រូវទាំងពីររដូវ។

## ***ការវិភាគពីខ្សែចង្វាក់តម្លៃ***

រចនាសម្ព័ន្ធទីផ្សារបានរៀបចំឡើងយ៉ាងល្អ ដោយមានបណ្តាញអ្នកប្រមូលទិញ ពាណិជ្ជករ អ្នកនាំចេញ រោងម៉ាស៊ីនកិនស្រូវ និងពាណិជ្ជករអន្តរជាតិ (រូបភាព ១)។ ទីផ្សារស្រូវមានប្រសិទ្ធភាពខ្ពស់ ដោយមានតួអង្គច្រើនរួមចំណែក និងការប្រកួតប្រជែងខ្លាំងតាមថ្លៃកំណត់ដោយកម្លាំងទីផ្សារ។ កសិករអាចលក់ស្រូវតាំងពីដើមឆ្នាំដល់ចុងឆ្នាំ ក្នុងទីផ្សារមានការប្រកួតប្រជែងខ្ពស់។ ព័ត៌មានអំពីថ្លៃតាមប្រភេទ និងគុណភាពស្រូវ មានធ្វើបច្ចុប្បន្នភាពស្ទើររាល់ថ្ងៃ ដែលបង្ហាញពីការប្រកួតប្រជែងខ្លាំង ដើម្បីបានប្រាក់ចំណេញ រវាងតួអង្គនៅក្នុងខ្សែចង្វាក់តម្លៃស្រូវ (Gergely *et al.* 2010)។

តារាង ៣ និង ៤ បង្ហាញពីមុខចំណាយលំអិត និងអត្រាចំណេញនៅក្នុងខ្សែចង្វាក់តម្លៃស្រូវ។ តម្លៃបន្ថែមរវាងតួអង្គស្ថិតនៅលំដាប់ជាប់គ្នាក្នុងខ្សែចង្វាក់តម្លៃ ត្រូវបានគណនាឡើងដោយផ្អែកលើព័ត៌មានអំពីថ្លៃទិញថ្លៃលក់ ប្រព័ន្ធផ្គត់ផ្គង់ ចំណាយដឹកជញ្ជូន និងអត្រាចំណេញ ដែលប្រមូលបាននៅពេលចុះសម្ភាសដល់កន្លែង ពីខែកុម្ភៈ ដល់ មីនា ២០១២។

កសិករធ្វើស្រែវស្សាភាគច្រើន លក់ស្រូវជាលក្ខណៈបុគ្គលទៅឲ្យអ្នកប្រមូលទិញតាមភូមិដោយគិតតាមថ្លៃទិញដល់កសិដ្ឋាន

តារាង១៖ ការវិភាគពីចំណេញដុលសម្រាប់ការដាំស្រូវ (ក្នុងមួយហិកតា)

| សកម្មភាព | រដូវវស្សា | | រដូវប្រាំង | |
|---|---|---|---|---|
| | ដុល្លារ | % | ដុល្លារ | % |
| ធាតុចេញ៖ ផលស្រូវ | 575 | 100 | 1396 | 100 |
| ធាតុចូល | | | | |
| ការរៀបចំដី | 40 | 7 | 90 | 6 |
| គ្រាប់ពូជ | 19 | 3 | 90 | 6 |
| ថ្លៃឈ្នួលពលកម្ម | 88 | 15 | 0 | 0 |
| ជីគីមី | 61 | 11 | 321 | 23 |
| ថ្នាំសម្លាប់សត្វចង្រៃ | 0 | 0 | 125 | 9 |
| ទឹកស្រោចស្រព | 75 | 13 | 160 | 11 |
| ការបោកបែន | 15 | 3 | 70 | 5 |
| ចំណាយធាតុចូលសរុប | 298 | 52 | 856 | 61 |
| ចំណេញដុល មិនគិតចូលនូវពលកម្មក្នុងគ្រួសារ | 277 | 48 | 540 | 39 |
| ចំណេញដុល មានគិតចូលនូវពលកម្មក្នុងគ្រួសារ | 150 | 26 | 297 | 21 |
| ផលត្រឡប់គិតក្នុងមួយថ្ងៃពលកម្មម្ចាស់កសិដ្ឋាន | 8.15 | | 8.31 | |
| ចំណាយ (ក្នុងមួយគីឡូក្រាម) | 0.13 | | 0.12 | |
| ចំណេញ (ក្នុងមួយគីឡូក្រាម) | 0.12 | | 0.07 | |

កំណត់សម្គាល់៖ អត្រាប្តូរប្រាក់ ១ដុល្លារ= ៤០០០រៀល។

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើការចុះសម្ភាសដល់កន្លែង នៅខែឧសភា ២០១២

តារាង ២៖ ថ្លៃស្រូវនៅកម្ពុជា (ដុល្លារ/តោន) ពីខែសីហា ២០១១ ដល់ តុលា ២០១១

| | កម្ពុជា | ថៃ | វៀតណាម | ការខុសថ្លៃគ្នា | |
|---|---|---|---|---|---|
| | | | | ថៃ | វៀតណាម |
| **ស្រូវអង្ករធម្មតា** | | | | | |
| ថ្លៃនៅកសិដ្ឋាន | 250-350 | 340-350 | 340-350 | 90-0 | 90-0 |
| អង្ករកិនរួច | 650 | 490-493 | 461 | 157-160 | 89 |
| ថ្លៃនាំចេញ (FOB) | 680 | 605-610 | 565-575 | 70-75 | 105-115 |
| **ស្រូវអង្ករក្រអូប** | | | | | |
| ថ្លៃនៅកសិដ្ឋាន | 354-452 | 402-452 | - | 47-0 | - |
| អង្ករកិនរួច | 870 | 907-910 | - | 37-40 | - |
| ថ្លៃនាំចេញ (FOB) | 900 | 1075-1085 | 675-685 | 175-185 | 185-225 |

សម្គាល់៖ FOB = ថ្លៃទំនិញដឹកដល់លើនាវា
ប្រភព៖ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១១

ប្រហែល ០,២៥ដុល្លារ/គីឡូក្រាម (២៥០ដុល្លារ/តោន)។ អ្នកប្រមូលទិញតាមភូមិត្រូវចេញថ្លៃលើកដាក់ស្រូវ សម្ភារៈផ្ទុកស្រូវ (បាវ, ខ្សែ, ធុង) និងថ្លៃដឹកជញ្ជូន ដែលសរុបមកអស់ប្រហែល ៣,៤ដុល្លារ ឬ ១,៤% នៃថ្លៃស្រូវទិញដល់កសិដ្ឋានសម្រាប់ស្រូវវស្សាប្រភេទចម្រុះ។ ពួកគេតម្លើងថ្លៃស្រូវប្រហែល ៣,៦% ឬស្មើនឹង អប្បហារ ៩ដុល្លារ/តោន ដែលធ្វើឲ្យតម្លៃស្រូវសម្រាប់អ្នកប្រមូលទិញឡើងដល់ ២៦៣ដុល្លារ/តោន។ អប្បហារ ២២% (៥៥ដុល្លារ/តោន) យកដោយពាណិជ្ជករតាមភូមិ វាមានកម្រិតខ្ពស់បើធៀបនឹង អប្បហារ ១៦% (៤០ដុល្លារ/តោន) យកដោយពាណិជ្ជករថ្នាក់តំបន់ ខណៈដែលពាណិជ្ជករតាមភូមិត្រូវចំណាយលើការផ្គត់ផ្គង់ និងដឹកជញ្ជូន (៧,៥ដុល្លារ/តោន) អស់តិចជាង ពាណិជ្ជករតាមតំបន់ (១០ដុល្លារ/តោន)។ នៅពេលទៅដល់រោងកិនស្រូវ ស្រូវឡើងថ្លៃដល់ ៣៧៧ដុល្លារ/តោន ឬកើន ៥០% ធៀបនឹងថ្លៃទិញស្រូវដល់កសិដ្ឋាន (២៥០ដុល្លារ/តោន)។

ខុសប្លែកពីកសិករធ្វើស្រែវស្សា កសិករធ្វើស្រែប្រាំងដាំស្រូវសម្រាប់គោលដៅពាណិជ្ជកម្ម ដូច្នេះ តួអង្គក្នុងខ្សែចង្វាក់តម្លៃស្រូវប្រាំងគាត់សកម្មជាខ្លាំង ឯការជួញដូរក៏មានការប្រកួតប្រជែងខ្លាំងដែរ។ ស្រូវលក់ដូរនៅរដូវប្រាំង ភាគច្រើនប្រើពូជ IR ដែលផ្តល់ស្រូវមានគុណភាពអន់ជាងពូជស្រូវវស្សា ហើយថ្លៃលក់នៅកសិដ្ឋានក៏ទាបជាងដែរ ប្រហែល ១៩៣ដុល្លារ/តោន (តារាង ៤)។ ដូចស្រូវវស្សាដែរ តម្លៃបន្ថែមលើថ្លៃលក់ដូរនៅកសិដ្ឋានកើតមានឡើងដោយសារចំណាយលើការលើកដាក់ ដឹកជញ្ជូន និងកម្រៃក្រៅផ្លូវការ។ ប៉ុន្តែកម្រិតអប្បហាររវាងតួអង្គស្ថិតនៅក្នុងខ្សែចង្វាក់តម្លៃ មិនសូវប្រែប្រួលខ្លាំងដូចក្នុងខ្សែចង្វាក់តម្លៃស្រូវវស្សាទេ គឺត្រឹម ៣,៤% ទៅ ៧,៥% ឬ ប្រហែល ៧ដុល្លារ ទៅ ១៤ដុល្លារ/តោន។ ចំណុចនេះបង្ហាញថា ទីផ្សារស្រូវប្រាំងមានប្រសិទ្ធភាព និងការប្រកួតប្រជែងខ្លាំងជាងក្នុងចំណោមតួអង្គនានា ហើយក៏មានព័ត៌មានថ្មីៗជាប់រហូតអំពីថ្លៃស្រូវដែរ។

### ទំនាក់ទំនង អភិបាលកិច្ច និងបញ្ហាប្រឈមក្នុងខ្សែចង្វាក់តម្លៃទីផ្សារស្រូវ

រូបភាព ៤ បង្ហាញពីការសម្របសម្រួល និងដំណើរការផ្លាស់ប្តូរព័ត៌មានគ្នាក្នុងខ្សែចង្វាក់តម្លៃស្រូវ នៅខេត្តតាកែវ។ ពាណិជ្ជករវៀតណាមកំណត់ថ្លៃ គុណភាព និងបរិមាណស្រូវ ហើយកសិករជាអ្នកទទួលយកថ្លៃនោះ។ ពាណិជ្ជករកម្ពុជា មានអំណាច

តារាង ៣៖ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវវស្សា (ដុល្លារ/តោន)

| | អ្នកប្រមូលទិញតាមភូមិ | | ពាណិជ្ជករក្នុងភូមិ/មូលដ្ឋាន | | ពាណិជ្ជករកម្រិតតំបន់ | | ម្ចាស់រោងកិនស្រូវខេត្ត | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារ | % | ដុល្លារ | % | ដុល្លារ | % | ដុល្លារ | % |
| ទិញចូល | 250.0 | 100.0 | 262.5 | 105.0 | 325.0 | 130.0 | 375.0 | 150.0 |
| លើកដាក់ស្រូវ | 1.0 | 0.4 | 2.0 | 0.8 | 2.0 | 0.8 | 2.0 | 0.8 |
| ដឹកជញ្ជូន | 1.4 | 0.6 | 4.1 | 1.6 | 5.0 | 2.0 | 0.0 | 0.0 |
| សម្ភារៈ | 1.0 | 0.4 | 1.5 | 0.6 | 1.5 | 0.6 | 0.0 | 0.0 |
| កម្រៃក្រៅផ្លូវការ | 0.0 | 0.0 | 0.0 | 0.0 | 1.5 | 0.6 | 0.0 | 0.0 |
| អប្បហារ | 9.1 | 3.6 | 54.9 | 22.0 | 40.0 | 16.0 | 0.0 | 0.0 |
| **សរុប** | **262.5** | **105.0** | **325.0** | **130.0** | **375.0** | **150.0** | **377.0** | **150.8** |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យបានពីការសម្ភាសដល់កន្លែង ខែឧសភា ២០១២

តារាង ៤៖ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវវស្សា (ដុល្លារ/តោន)

| | អ្នកប្រមូលទិញតាមភូមិ | | ពាណិជ្ជករក្នុងភូមិ/មូលដ្ឋាន | | ពាណិជ្ជករថ្នាក់តំបន់ | | អ្នកនាំចេញ | | ពាណិជ្ជករវៀតណាម | |
|---|---|---|---|---|---|---|---|---|---|---|
| | USD | % | USD | % | USD | % | USD | % | USD | % |
| ទិញចូល | 192.5 | 100.0 | 202.5 | 105.2 | 217.5 | 113.0 | 237.5 | 123.4 | 262.5 | 136.4 |
| លើកដាក់ស្រូវ | 1.0 | 0.5 | 2.0 | 1.0 | 2.0 | 1.0 | 2.0 | 1.0 | 2.0 | 1.0 |
| ដឹកជញ្ជូន | 1.4 | 0.7 | 4.1 | 2.1 | 5.0 | 2.6 | 5.0 | 2.6 | 0.0 | 0.0 |
| សម្ភារៈ | 1.0 | 0.5 | 1.5 | 0.8 | 1.5 | 0.8 | 1.5 | 0.8 | 0.0 | 0.0 |
| កម្រៃក្រៅផ្លូវការ | 0.0 | 0.0 | 0.0 | 0.0 | 1.5 | 0.8 | 2.0 | 1.0 | 0.0 | 0.0 |
| អប្បហារ | 6.6 | 3.4 | 7.4 | 3.8 | 10.0 | 5.2 | 14.5 | 7.5 | 0.0 | 0.0 |
| **សរុប** | **202.5** | **105.1** | **217.5** | **112.9** | **237.5** | **123.4** | **262.5** | **136.3** | **264.5** | **137.4** |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យបានពីការសម្ភាសដល់កន្លែង ខែឧសភា ២០១២

តិចតួចក្នុងការចរចាពីថ្លៃ និងគុណភាពស្រូវជាមួយពាណិជ្ជករវៀតណាម។ គុណភាពហាក់មិនមែនជាបញ្ហាធំដុំទេនៅពេលមានតម្រូវការខ្ពស់ ប៉ុន្តែជារឿយៗពាណិជ្ជករវៀតណាមបានយកប្រៀប និងបន្ទាបគុណភាពដើម្បីបញ្ចុះថ្លៃស្រូវ។

នាបច្ចុប្បន្ន មិនទាន់មានយន្តការត្រួតពិនិត្យគុណភាពជាលក្ខណៈប្រព័ន្ធ ឬផ្លូវការណាមួយសម្រាប់ធ្វើចំណាត់ថ្នាក់គុណភាពស្រូវនៅតាមដំណាក់កាលនីមួយៗនៃខ្សែចង្វាក់តម្លៃទេ។ តួអង្គនានាត្រូវធ្វើការវាយតម្លៃគុណភាពស្រូវដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍របស់ខ្លួន ហើយលក្ខណៈវិនិច្ឆ័យចម្បង គឺបរិមាណសំណើម និងភាពផ្លូវនៃស្រូវ។

### *គោលនយោបាយស្រូវ*

តាកែវជាខេត្តផលិតស្រូវចម្បងមួយនៅកម្ពុជា ដោយរួមចំណែក ១២,៥% នៃផលិតកម្មស្រូវទូទាំងប្រទេស និង ១៧,៦% នៃអតិរេកស្រូវសរុប ពោលគឺជាខេត្តដ៏សំខាន់មួយសម្រាប់សម្រេចគោលនយោបាយ "មាសស" របស់រដ្ឋាភិបាលដែលសំដៅនាំចេញស្រូវឲ្យបាន ១លានតោន នៅក្នុងឆ្នាំ២០១៥។ ទោះបីខេត្តតាកែវមានសក្តានុពលខ្ពស់ដើម្បីផលិតអតិរេកស្រូវសម្រាប់ការនាំចេញក្តី ក៏នៅមានចំណុចខ្វះខាតជាច្រើន ដូចជា ពូជមានគុណភាពអន់ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅមានកម្រិត និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់សម្រាប់ទិញលក់ស្រូវ ក្រោយពេលប្រមូលផល។

**ពូជស្រូវ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំឲ្យប្រើនិងជំរុញពូជស្រូវ១០មុខក្នុងនេះមានទាំងស្រូវស្រាលបីមុខ គឺសែនពិដោរ, IR66 និង ផលសារ ដែលមានសក្តានុពលក្នុងការផលិតស្រូវឲ្យបានស្របតាមស្តង់ដារនាំចេញ។ ទោះយ៉ាងនេះក្តី កសិករនៅតែបន្តប្រើពូជស្រូវ IR504 មកពីវៀតណាម ជាជាងពូជស្រូវក្នុងស្រុកដែលក្រសួងកសិកម្ម បានជំរុញសម្រាប់ទីផ្សារនាំចេញ។ ពូជស្រូវ IR504 មានប្រើយ៉ាងទូលំទូលាយក្នុងតំបន់មានប្រព័ន្ធស្រោចស្រព និងតំបន់ធ្វើស្រូវប្រជេញទឹក ដោយមានចំណែកប្រហែល ៤១% នៃផលិតកម្មស្រូវសរុបនៅខេត្តតាកែវ។ ទោះបីនៅទីផ្សារក្នុងស្រុកគេចាត់ទុកថា ពូជស្រូវនេះមានគុណភាពអន់ក្តី ប៉ុន្តែទិន្នផលខ្ពស់ និងតម្រូវការខ្ពស់ពីពាណិជ្ជករវៀតណាម បានជំរុញកសិករឲ្យដាំស្រូវប្រភេទនេះជាលក្ខណៈពាណិជ្ជកម្ម។

**ពូជគុណភាពអន់៖** កសិករនៅតែបន្តប្រើគ្រាប់ពូជគុណភាពអន់។ ទោះបីមានការរីកចម្រើនខាងជំនាញឯកទេសក្តី ក៏ការផ្គត់ផ្គង់គ្រាប់ពូជ នៅតែមិនទាន់បានគ្រប់គ្រាន់នៅតាមតំបន់ជាច្រើននៅកម្ពុជា ក្នុងនេះមានទាំងខេត្តតាកែវផង។ កសិករភាគច្រើនមិនបានប្តូរគ្រាប់ពូជជាថ្មីឲ្យបានទៀងទាត់ទេ ហើយរបៀបទុកដាក់គ្រាប់ពូជមិនល្អបានធ្វើឲ្យវាលាយឡំចូលគ្នា និងថយចុះអត្រាដុះលូតលាស់ និងគុណភាពជាពូជសុទ្ធ ពីមួយរដូវទៅមួយរដូវ។ កសិករ (ជាពិសេសកសិករធ្វើស្រែវស្សា) តែងផ្លាស់ប្តូរគ្រាប់ពូជ តែក្រោយពេលអ្នកប្រមូលទិញ និងម្ចាស់រោងកិនស្រូវទាមទារនូវស្រូវមានគុណភាពល្អជាងមុន ឬ ដើម្បីទទួលបានថ្លៃខ្ពស់សម្រាប់ផលស្រូវរបស់ខ្លួន។

**កង្វះសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម៖** កសិករត្អូញត្អែរពីបញ្ហាលទ្ធភាពទទួលបានជំនួយបច្ចេកទេស ពីអាជ្ញាធរមូលដ្ឋានដើម្បីគ្រប់គ្រងលើបញ្ហាសត្វចង្រៃជាពិសេសនៅរដូវប្រាំង។ពួកគេមានប្រើថ្នាំសម្លាប់សត្វចង្រៃជាច្រើនប្រភេទ ប៉ុន្តែថ្នាំទាំងនោះខ្លះជាទំនិញហាមឃាត់ និងប៉ះពាល់អាក្រក់ដល់សុខភាព និងបរិស្ថាន។ ថ្នាំសម្លាប់សត្វចង្រៃលក់លើទីផ្សារ ភាគច្រើននាំចូលពីវៀតណាម ឬ ថៃ និងមានសេចក្តីណែនាំពីរបៀបប្រើសរសេរជាភាសាវៀតណាម ឬថៃ ហើយកសិករមិនអាចមើលយល់ពីរបៀបត្រូវប្រុងប្រយ័ត្ន ឬរបៀបលាយនិងប្រើប្រាស់ថ្នាំទាំងនោះទេ។ កង្វះសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការណែនាំពីវិធីប្រើជី ធ្វើឲ្យកសិករត្រូវពឹងផ្អែកលើការណែនាំរបស់ឈ្មួញ ឬក៏ ប្រើជីទៅតាមកម្រិត/បរិមាណ ដែលគាត់មានលទ្ធភាពរកបាន។ ការត្រួតពិនិត្យអន់ខ្សោយនៅតាមច្រកព្រំដែន បានបើកផ្លូវឲ្យជីគ្មានស្តង់ដារហូរចូលមកក្នុងទីផ្សារ។លើសពីនេះទៀតប្រហែល១០% នៃជីលក់លើទីផ្សារជាជីមានការលាយបន្លំ ឬមានគុណភាពទាបដែលគេបានវេចខ្ចប់ជាថ្មី ដោយប្រើបាវមានដាក់ផ្លាកសញ្ញានៃជីគុណភាពខ្ពស់ៗ (Theng 2012)។

**ទីផ្សារស្រូវ៖** ប្រហែល ៦៩% (៧៦៤.៩០២តោន) នៃ

រូបភាព ៤៖ ការសម្របសម្រួលផ្តល់ព័ត៌មានក្នុងខ្សែចង្វាក់តម្លៃ




ផលិតកម្មស្រូវសរុបនៅខេត្តតាកែវ ជាអតិរេកស្រូវ ដែលបង្ហាញពីសក្តានុពលដ៏ធំសម្រាប់ការនាំចេញ។ ប៉ុន្តែកង្វះវិនិយោគជាមូលធនទៅលើរោងកិនស្រូវ និងបច្ចេកវិទ្យាកិនស្រូវទំនើបៗ បានកាត់បន្ថយសមត្ថភាពកែច្នៃអតិរេកស្រូវនេះ ធ្វើឲ្យស្រូវមួយភាគធំត្រូវបាននាំចេញ ជាពិសេសទៅកាន់ប្រទេសវៀតណាម។ ពាណិជ្ជករវៀតណាម ហាក់ដូចអាចគ្របដណ្តប់បានលើពាណិជ្ជកម្មស្រូវនេះ ដោយពួកគេជាអ្នកកំណត់ថ្លៃ និងស្តង់ដាគុណភាព ហើយក៏អាចឆ្លៀតឱកាសបន្ទាបគុណភាព និងបញ្ចុះថ្លៃស្រូវ។ ដូច្នេះ កម្ពុជាចាំបាច់ត្រូវចាត់វិធានការដើម្បីធ្វើចំណាត់ថ្នាក់គុណភាពស្រូវ ដែលអាចធ្វើឲ្យពាណិជ្ជកម្មមានលក្ខណៈយុត្តិធម៌សម្រាប់ភាគីទាំងសងខាង។

## ការពាក់ព័ន្ធដល់គោលនយោបាយ

កសិករត្រូវប្រឈមមុខនឹងចំណាយផលិតកម្មខ្ពស់ និងថ្លៃទិញលក់ទាបៗនៅកសិដ្ឋាន។ ចំណុចនេះបង្ហាញពីតម្រូវការកាត់បន្ថយចំណាយផលិតកម្ម ជាពិសេសចំណាយហួសពីសមត្ថភាពគ្រប់គ្រងរបស់ផលិតករ និងកែលំអថ្លៃទិញលក់នៅកសិដ្ឋានសម្រាប់ទាំងស្រូវប្រាំង និងស្រូវវស្សា។

ការវិភាគខ្សែចង្វាក់តម្លៃបង្ហាញថា ស្រូវនៅខេត្តតាកែវមិនទាន់បំពេញបានតាមស្តង់ដារសម្រាប់នាំចេញទេ។ សកម្មភាពផ្សេងៗដែលគួរពិចារណាសម្រាប់ផ្នែកផលិតកម្មរួមមានការណែនាំឲ្យប្រើពូជស្រូវមានគុណភាពល្អ ការចែកចាយនិងផ្លាស់ប្តូរគ្រាប់ពូជជាថ្មីឲ្យបានទៀងទាត់ និងការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មស្តីពី វិធីល្អៗក្នុងការដាំស្រូវ ដូចជា ការគ្រប់គ្រងបញ្ហាសត្វចង្រៃ និងការកែលំអគុណភាពដី និងការប្រើជី។ សកម្មភាពទាំងនេះអាចឲ្យកសិករកាត់បន្ថយចំណាយផ្សេងៗ ជាពិសេសទៅលើជី និងថ្នាំសម្លាប់សត្វចង្រៃ ព្រមទាំងទទួលបានទិន្នផលស្រូវកាន់តែខ្ពស់ និងមានគុណភាពស្របតាមស្តង់ដារនាំចេញ ដែលនឹងផ្តល់នូវថ្លៃទីផ្សារកាន់តែប្រសើរ។

ទីផ្សារស្រូវមានរចនាសម្ព័ន្ធល្អនៅខេត្តតាកែវ ជួយឲ្យកសិករអាចលក់ស្រូវបានតាមតម្លៃទីផ្សារប្រកួតប្រជែង។ អតិរេកស្រូវគេអាចកិនវា និងលក់ដូរវាប្រកបដោយប្រសិទ្ធភាពនៅក្នុងទីផ្សារមូលដ្ឋាន ប៉ុន្តែសមត្ថភាពកិនស្រូវកម្រិតទាប និងកង្វះវិនិយោគជាមូលធន ធ្វើឲ្យផ្នែកកិនស្រូវនេះមិនអាចកែច្នៃអតិរេកស្រូវទាំងអស់បានទេ។ ដូច្នេះការនាំចេញស្រូវនៅតែសំខាន់បំផុត ប៉ុន្តែនាបច្ចុប្បន្ន អតិរេកស្រូវត្រូវបានដោះដូរតែជាមួយប្រទេសវៀតណាមប៉ុណ្ណោះ។ កម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយប្រទេសវៀតណាម ដើម្បីនាំចេញ និងនាំចូលស្រូវ ប៉ុន្តែការផ្លាស់ប្តូរក្នុងគោលនយោបាយពាណិជ្ជកម្មស្រូវអង្កររបស់វៀតណាម តាមរយៈការយកពន្ធគយកាន់តែច្រើន ការកំណត់កូតា ឬការបិទព្រំដែនដើម្បីការពារទីផ្សារក្នុងស្រុក អាចធ្វើឲ្យវិស័យស្រូវនៅខេត្តតាកែវ ជួបនឹងវិបត្តិ។ វិធានការសុវត្ថិភាពសេដ្ឋកិច្ចដ៏សំខាន់មួយ សម្រាប់ទប់ទល់នឹងហានិភ័យនៃការរអាក់រអួលបែបនេះ គឺការបើកដំណើរការនូវខ្សែចង្វាក់នាំចេញស្រូវរបស់កម្ពុជាមួយឡើង៕

ឯកសារយោងមាននៅក្នុងអត្ថបទជាអង់គ្លេស

*តពីទំព័រ ៤* **កំណែទម្រង់វិស័យជលផល...**

ទៅតាមតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន ហើយវាអាចបង្កើតឲ្យមានភាពតានតឹងរវាងសហគមន៍ នឹងអង្គភាពប្រតិបត្តិច្បាប់។ ប៉ុន្តែភាពយឺតយ៉ាវពេកក្នុងការសម្រេចចិត្ត ឬដាក់អនុវត្តច្បាប់ថ្មីៗក៏អាចបង្កជាបញ្ហាផងដែរ។ ដូច្នេះ ការស្វែងរកផ្លូវកណ្តាល ដើម្បីសម្រេចបានទាំងការចូលរួមប្រកបដោយប្រសិទ្ធភាព និងការអនុវត្តទាន់ពេលវេលានោះ មិនមែនជាការងាយស្រួលឡើយ។

ឯកឧត្តមអគ្គនាយកប្រធានរដ្ឋបាលជលផល បានបញ្ជាក់នៅក្នុងវេទិកាអង្គសិក្ខាសាលានោះថា ការអនុវត្តកំណែទម្រង់វិស័យជលផលបាន និងកំពុងជួបប្រទះបញ្ហាប្រឈមជាបន្តបន្ទាប់ ដូច្នេះ ត្រូវមានការប្រាស្រ័យទាក់ទងគ្នាជាចំហ រវាងតួអង្គពាក់ព័ន្ធទាំងអស់ និងត្រូវមានឆន្ទៈក្នុងការពិសោធន៍សាកល្បង និងរៀនសូត្ររួមគ្នា។ ការប្តេជ្ញាចិត្តធ្វើការពិសោធន៍សាកល្បង និងរៀនសូត្ររួមគ្នា ត្រូវមានដំណើរការអនុវត្តន៍នូវគំនិតច្នៃប្រឌិតថ្មីៗថែមទៀត ដើម្បីបំផុសគំនិតបែបថ្មីនៅថ្នាក់មូលដ្ឋាន ចងក្រងមេរៀនបទពិសោធន៍ដែលរៀនសូត្របាន ហើយយកទៅប្រើប្រាស់ ក្នុងកិច្ចខំប្រឹងប្រែងធ្វើកំណែទម្រង់ស្ថាប័ន និងគោលនយោបាយដែលទាក់ទងទៅនឹងវិស័យជលផលនាពេលអនាគត។ ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ និងភ្នាក់ងារជលផលនៅតាមមូលដ្ឋានក៏ត្រូវមានសមត្ថភាពនិងចំណេះដឹងថ្មីៗបន្ថែមទៀត ដើម្បីជួយទ្រទ្រង់ដល់ការអនុវត្តវិធីសាស្រ្តនេះ។

បឹងទន្លេសាបជាប្រព័ន្ធអេកូឡូស៊ីមួយដ៏ធំទូលាយ មានលក្ខណៈស្មុគស្មាញ និងងាយខ្ទេចខ្ទាំ។ ប្រព័ន្ធនេះបានជួយទ្រទ្រង់ដល់

*តទៅទំព័រ ១៨*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះរៀបរាប់ពី សូចនាករនៃសេដ្ឋកិច្ចសំខាន់ៗនៅក្នុងពិភពលោក នៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

ភាពមិនប្រាកដប្រជា និងងាយរងគ្រោះក្នុងសេដ្ឋកិច្ចពិភពលោកនៅតែមានជាបន្ត ដោយសារសេដ្ឋកិច្ចប្រទេសធំៗនៅតំបន់អាស៊ី និងប្រទេសឧស្សាហកម្មថ្មីៗបន្តឡើងចុះ និងមានកំណើនយឺតជាងមុន។ សេដ្ឋកិច្ចតំបន់អាស៊ីនៅតែជា កម្លាំងជំរុញដល់ការរើបឡើងនៃសេដ្ឋកិច្ចពិភពលោក ទោះបីជាការជំរុញនេះមានល្បឿនយឺតជាងមុនក្តី។

នៅត្រីមាសទី១ កំណើន ផសស ពិតនៅឥណ្ឌូនេស៊ីធ្លាក់ចុះបន្តិចមកត្រឹម ៦,០% ធៀបនឹង ៦,១% កាលពីត្រីមាសមុន និង ៦,៣% កាលពីមួយឆ្នាំមុន។ កំណើន ផសស ពិតនៅម៉ាឡេស៊ី ធ្លាក់ចុះមកត្រឹម ៤,១% ធៀបនឹង ៤,៧% កាលពីមួយឆ្នាំមុន។ កំណើន ផសស នៅសិង្ហបុរី ធ្លាក់ចុះទាបបំផុតគិតចាប់ពីឆ្នាំ២០១០ មកនៅត្រឹម ០,២% ធៀបនឹង ១,៦% កាលពីមួយឆ្នាំមុន។ ប្រទេសចិននៅតែមាន ការរីកលូតលាស់សេដ្ឋកិច្ចយ៉ាងលឿនបំផុតមួយ ដោយមានកំណើន ផសស ៧,៧% នៅត្រីមាសទី១ ពោលគឺធ្លាក់ចុះបន្តិចបើធៀបនឹងកំណើន ៧,៩% កាលពីត្រីមាសមុន។ សេដ្ឋកិច្ចចិនអាចមានកំណើនយឺតថែមទៀត ដែលនឹងជះឥទ្ធិពលទៅលើទីផ្សារផលិតផល និងអ្នកប្រើប្រាស់ទាំងនៅក្នុងស្រុក និងអន្តរជាតិ។ ក្នុងករណីនេះ ចិនប្រហែលត្រូវពិចារណាធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធ ដើម្បីសម្រេចបានកំណើនលឿន និងមានចីរភាព។ ទោះបីជម្លោះដណ្តើមកោះមួយចំនួន រវាងចិននិងជប៉ុន និង រវាងចិននិងប្រទេសជាច្រើនទៀតនៅអាស៊ីអាគ្នេយ៍ បានធូរស្រាលខ្លះវិញក្តី ក៏ចិនត្រូវតែខិតខំដោះស្រាយជម្លោះដោយសន្តិវិធី ដើម្បីធានាឲ្យមានលំហូររលូនល្អនៃវិនិយោគ និងពាណិជ្ជកម្មក្រៅប្រទេស។ កំណើន ផសស ពិតនៅហុងកុងកើនដល់ ២,៨% ធៀបនឹង ២,៥% នៅត្រីមាសមុន ប៉ុន្តែនៅកូរ៉េខាងត្បូង កំណើន ផសស ធ្លាក់ចុះមកត្រឹម ១,៥% ធៀបនឹង ១,៦% កាលពីត្រីមាសមុន។

កិច្ចប្រឹងប្រែងជំរុញ កំណើនសេដ្ឋកិច្ចឡើងវិញនៅតំបន់អឺរ៉ូ សម្រេចបានជោគជ័យមួយកម្រិត ដោយទទួលបានកំណើនវិជ្ជមាននៅត្រីមាសទី១ បន្ទាប់ពីមានកំណើនអវិជ្ជមានអស់បីត្រីមាសជាបន្តបន្ទាប់។ នៅត្រីមាសទី១ កំណើន ផសស នៅតំបន់អឺរ៉ូ កើនដល់ ១,១% ធៀបនឹង -០,៩% កាលពីត្រីមាសមុន។ សេដ្ឋកិច្ចជប៉ុនក៏រីកលូតលាស់យឺតដែរ ដោយមានកំណើន ០,៤% ធៀបនឹង ២,៨% កាលពីឆ្នាំមុន។ សហរដ្ឋអាមេរិកបន្តមានដំណើរការសេដ្ឋកិច្ចល្អ បើធៀបនឹងប្រទេសមានសេដ្ឋកិច្ចជឿនលឿនដទៃទៀត ដោយមានកំណើន ១,៨% ធៀបនឹង ១,៦% កាលពីត្រីមាសមុន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ សេដ្ឋកិច្ចស្ទើរតែទាំងអស់អាចគ្រប់គ្រងអតិផរណាបានល្អ។ អតិផរណានៅកម្ពុជាធ្លាក់ចុះមកត្រឹម ១,៥% ធៀបនឹង ១,៨% កាលពីត្រីមាសមុន និង ៥,៥% កាលពីឆ្នាំមុន។ អតិផរណានៅវៀតណាមបន្តថយចុះវិញមកត្រឹម ៦,៩% ធៀបនឹង ១៦,០% កាលពីឆ្នាំមុន។ ជប៉ុនមានការធ្លាក់ចុះថ្លៃទំនិញសរុប ដែលដាក់សម្ពាធបង្កើនអត្រាការប្រាក់ពិត។ បរិត្តផរណាបន្តកើតមាននៅជប៉ុន ទោះបីរដ្ឋាភិបាលបានអនុវត្តវិធានការបង្កើនចំណាយយ៉ាងច្រើន តាមគោលនយោបាយ "Abenomics" ក៏ដោយ។

នៅត្រីមាសទី១ ប្រាក់រៀលឡើងថ្លៃ ០,០២% ធៀបនឹងត្រីមាសមុន (១,៣% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ។ ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ីចុះថ្លៃ ០,៧% (៦,៦% ធៀបនឹងមួយឆ្នាំមុន) ហើយប្រាក់រីងហ្គិតម៉ាឡេស៊ីនៅថេរ។ ប្រាក់បាតថៃឡើងថ្លៃ ២,៩% (៣,៨% ធៀបនឹងមួយឆ្នាំមុន)។ ប្រាក់អឺរ៉ូនៅថេរទល់នឹងប្រាក់ដុល្លារ រីឯប្រាក់យេនជប៉ុនធ្លាក់ថ្លៃ ១៣,៥% (១៦,៤% ធៀបនឹងមួយឆ្នាំមុន) ដែលបានជួយបង្កើនភាពប្រកួតប្រជែងផ្នែកនាំចេញរបស់ជប៉ុន។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី១ ពោត (US No. 2) ចុះថ្លៃ ១,៨% មកត្រឹម ៣០៥,២ដុល្លារ/តោនប៉ុន្តែឡើងថ្លៃ១០,០%ធៀបនឹងមួយឆ្នាំមុន។ ប្រេងឆាឡើងថ្លៃ ៥,៤% (ចុះថ្លៃ ២៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ៨៥២,៧ដុល្លារ/តោន ហើយកៅស៊ូ (SMR5) ឡើងថ្លៃ ៣,០% (ចុះថ្លៃ ១៨,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣០២៩,៥ដុល្លារ/តោន។ ក្នុងត្រីមាសដដែល អង្ករថៃ (100% B) ចុះថ្លៃ ០,៤% (ឡើងថ្លៃ ៨,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ៥៩៤,៧ដុល្លារ/តោន ហើយសណ្តែកសៀង (US No.1) ចុះថ្លៃ ៣,៤% (ឡើងថ្លៃ ១៣,៨% ធៀបនឹងមួយឆ្នាំមុន) ដល់ ៥៥៨,៤ដុល្លារ/តោន។ ប្រេងឆៅ (OPEC spot) ឡើងថ្លៃ ២,១% (ចុះថ្លៃ ៦,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ១០៩,៥ដុល្លារ/ធុង។ សាំង (US Gulf Coast) ចុះថ្លៃ ៣,៣% ( ១០,១% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ០,៧១ដុល្លារ/លីត្រ។ ម៉ាស៊ូត (low sulphur No. 2) ឡើងថ្លៃ ១,៥% ធៀបនឹងត្រីមាសមុន ដល់ ០,៨២ដុល្លារ/លីត្រ ប៉ុន្តែចុះថ្លៃ ២,៧% បើធៀបនឹងមួយឆ្នាំមុន។

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2008 | 2009 | 2010 | 2011 | | | | 2012 | | | | 2013 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.8 | 0.1 | - | - | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.1 | 4.2 | 6.2 | 6.5 | 6.5 | 6.5 | 6.5 | 6.3 | 6.4 | 6.2 | 6.1 | 6.0 |
| ម៉ាឡេស៊ី | 4.6 | -2.4 | 9.0 | 4.6 | 4.0 | 5.8 | 5.2 | 4.7 | 5.4 | 5.2 | 6.4 | 4.1 |
| សិង្ហបុរី | 1.1 | -4.5 | 14.7 | 8.3 | 0.9 | 5.9 | 3.6 | 1.6 | 1.9 | 0.3 | 1.5 | 0.2 |
| ថៃ | 2.6 | 3.3 | 7.9 | 3 | 2.6 | 3.5 | -9.0 | 0.0 | 4.2 | 3.3 | 19.5 | 5.4 |
| វៀតណាម | 6.2 | 4.7 | 6.7 | 5.4 | 5.7 | 7.2 | 6.1 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.0 | 8.2 | 10.4 | 9.7 | 9.5 | 9.1 | 8.9 | 8.1 | 7.6 | 7.4 | 7.9 | 7.7 |
| ហុងកុង | 2.4 | -3.2 | 6.9 | 7.2 | 5.1 | 4.3 | 3.0 | 4.2 | 3.6 | 1.3 | 2.5 | 2.8 |
| កូរ៉េខាងត្បូង | 2.2 | -1.0 | 6.1 | 4.2 | 3.4 | 3.4 | 3.4 | 3.0 | 2.4 | 1.5 | 1.6 | 1.5 |
| តៃវ៉ាន់ | 0.1 | -3.6 | 11.1 | 6.5 | 4.9 | 3.4 | 1.9 | 0.4 | -0.2 | 1.0 | 3.7 | 1.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.9 | -3.8 | 1.6 | 2.5 | 1.6 | 1.4 | 0.7 | 0.0 | -0.4 | -0.6 | -0.9 | 1.1 |
| ជប៉ុន | -0.7 | -5.4 | 4.1 | -1 | -1.0 | 0.0 | -1.0 | 2.8 | 3.5 | 0.1 | 0.5 | 0.4 |
| សហរដ្ឋអាមេរិក | 1.1 | -2.5 | 2.7 | 2.3 | 1.5 | 1.6 | 1.6 | 2.1 | 2.2 | 2.5 | 1.6 | 1.8 |

Sources: IMF, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | | 2012 | | | | 2013 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 19.7 | -0.5 | 4.1 | 5.5 | 6.2 | 6.7 | 4.9 | 5.5 | 2.9 | 1.6 | 1.8 | 1.5 |
| ឥណ្ឌូណេស៊ី | 10.1 | 4.7 | 5.1 | 3.8 | 5.9 | 4.7 | 4.1 | 3.8 | 4.5 | 4.5 | 4.4 | 5.3 |
| ម៉ាឡេស៊ី | 5.3 | 0.4 | 1.7 | 2.3 | 3.3 | 3.4 | 3.2 | 2.3 | 1.7 | 1.4 | 1.3 | 1.4 |
| សិង្ហបុរី | 6.5 | 0.5 | 2.9 | 4.9 | 4.7 | 5.5 | 5.5 | 4.9 | 5.2 | 4.2 | 4.0 | 3.6 |
| ថៃ | 5.5 | -0.9 | 3.1 | 3.4 | 4.1 | 4.1 | 4.0 | 3.4 | 2.6 | 2.9 | 3.2 | 3.1 |
| វៀតណាម | 23.3 | 7.3 | 9.0 | 16.0 | 19.4 | 22.5 | 19.8 | 16.0 | 8.6 | 5.6 | 7.0 | 6.9 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.9 | -0.8 | 3.2 | 3.8 | 5.7 | 6.3 | 4.6 | 3.8 | 2.9 | 1.9 | 2.1 | 2.4 |
| ហុងកុង | 4.3 | -0.3 | 2.4 | 5.2 | 5.1 | 6.5 | 5.7 | 5.2 | 4.2 | 3.1 | 3.8 | 2.2 |
| កូរ៉េខាងត្បូង | 4.6 | 2.8 | 3.0 | 2.9 | 4.2 | 4.8 | 4.1 | 2.9 | 2.4 | 1.6 | 1.7 | 1.4 |
| តៃវ៉ាន់ | 3.2 | -1.1 | 1.0 | 1.3 | 1.6 | 1.3 | 1.4 | 1.3 | 1.6 | 3.0 | 1.9 | 1.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 3.3 | 0.4 | 1.6 | 2.7 | 2.7 | 2.7 | 2.9 | 2.7 | 2.5 | 2.5 | 2.3 | 1.8 |
| ជប៉ុន | 1.4 | -1.3 | -0.7 | 0.3 | 0.3 | 0.2 | -0.3 | 0.3 | 0.2 | -0.4 | -0.2 | -0.3 |
| សហរដ្ឋអាមេរិក | 3.8 | -0.4 | 1.7 | 2.8 | 3.5 | 3.8 | 3.3 | 2.8 | 1.9 | 1.7 | 1.9 | 1.7 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | | 2012 | | | | 2013 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4054.2 | 4140.5 | 4187.1 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.2 | 3995.9 | 3995 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9699.0 | 10413.8 | 9089.9 | 8902.0 | 8593 | 8625.8 | 8985.7 | 9078.6 | 9281.3 | 9490.3 | 9614.6 | 9681.9 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.5 | 3.2 | 3.1 | 3.0 | 3.0 | 3.2 | 3.1 | 3.1 | 3.1 | 3.1 | 3.1 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.4 | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.6 | 1.2 | 1.2 |
| ថៃ (បាត) | 33.4 | 34.3 | 31.7 | 30.6 | 30.3 | 30.2 | 31.0 | 31.0 | 31.3 | 31.3 | 30.7 | 29.8 |
| វៀតណាម (ដុង) | 16382.0 | 17725.2 | 19200.8 | 20,273.8 | 20,693.6 | 20,699.6 | 20,997.7 | 20,971.2 | 20849.7 | 20847.5 | 20839.3 | 20829.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.9 | 6.8 | 6.76 | 6.6 | 6.5 | 6.4 | 6.36 | 6.3 | 6.3 | 6.4 | 6.2 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.77 | 7.8 | 7.8 | 7.8 | 7.78 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1137.2 | 1277.8 | 1156.3 | 1020.2 | 1084.3 | 1084.9 | 1144.87 | 1131.2 | 1152.6 | 1132.9 | 1089.9 | 1085.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.5 | 33.0 | 31.3 | 29.3 | 28.9 | 29.2 | 30.26 | 29.7 | 29.6 | 29.8 | 29.2 | 29.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.7 | 0.8 | 0.7 | 0.7 | 0.7 | 0.74 | 0.8 | 0.8 | 0.8 | 0.8 | 0.8 |
| ជប៉ុន (យ៉េន) | 102.5 | 93.6 | 87.8 | 82.3 | 81.7 | 77.9 | 77.78 | 79.3 | 80.1 | 78.6 | 81.3 | 92.3 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | | 2012 | | | | 2013 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 218.2 | 167.3 | 167.3 | 280.3 | 311.6 | 302.8 | 270.8 | 277.5 | 270.5 | 327.1 | 310.9 | 305.2 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 912.2 | 686.8 | 834.7 | 1251.0 | 1147.0 | 1079.0 | 1024.7 | 1106.7 | 1083.3 | 993.0 | 809.3 | 852.7 |
| កៅស៊ូ SMR 5 (USD/តោន) | 2586.3 | 1884.8 | 3152.2 | 5278.0 | 4968.8 | 4617.6 | 3658.0 | 3701.2 | 3361.0 | 2799.2 | 2941.5 | 3029.5 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 615.3 | 524.5 | 456.2 | 528.3 | 514.3 | 581.3 | 610.3 | 549.0 | 600.3 | 595.7 | 597.0 | 594.7 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 460.4 | 414.0 | 375.4 | 537.2 | 525.7 | 514.0 | 454.8 | 490.8 | 546.5 | 649.4 | 577.8 | 558.4 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 95.4 | 60.5 | 71.6 | 93.3 | 113.3 | 108.9 | 109.1 | 117.3 | 106.7 | 106.6 | 107.3 | 109.5 |
| សាំង - US Gulf Coast (សេន/លីត្រ) | 62.2 | 42.9 | 49.8 | 63.2 | 78.7 | 74.6 | 68.5 | 79.0 | 74.0 | 71.6 | 73.4 | 71.0 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 76.20 | 43.05 | 51.6 | 72.5 | 75.7 | 77.3 | 77.3 | 83.8 | 77.8 | 81.1 | 80.3 | 81.5 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[1]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ ឆ្នាំ២០១៣ ដំណើរការសេដ្ឋកិច្ចហាក់ដូចមិនគួរឲ្យមានសុទិដ្ឋិនិយមប៉ុន្មានទេ ដោយសារការថយចុះកំណើនក្នុងវិស័យសំខាន់ៗ ដែលជាសញ្ញាថា រដ្ឋាភិបាលគួរបង្កើនការយកចិត្តទុកដាក់ បើសិនចង់សម្រេចគោលដៅកំណើនសេដ្ឋកិច្ច ៧% ដូចបានរំពឹងទុកសម្រាប់ឆ្នាំនេះ។

នៅត្រីមាសទី១ វិនិយោគជាទ្រព្យសកម្មជាប់លាប់អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្លាក់ ៨១,១% ធៀបនឹងត្រីមាសមុន (៤៧,៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២១៨,៩ លានដុល្លារ ដែលមិនមែនជាសញ្ញាល្អសម្រាប់ អត្រាកំណើនរំពឹងទុក ៧% នោះឡើយ។ វិនិយោគខាងកសិកម្មធ្លាក់ ៩៨% ធៀបនឹងត្រីមាសមុន (៩៨,៥% ធៀបមួយឆ្នាំមុន) មក ២,៣ លានដុល្លារ ទោះបីរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្លាំងលើកកម្ពស់ ការប្រកួតប្រជែង និងផលិតភាពក្នុងវិស័យនេះ ពិសេសដំណាំស្រូវក្តី។ វិនិយោគខាងឧស្សាហកម្មដែលជាកម្លាំងជំរុញកំណើនសំខាន់មួយ បានធ្លាក់ ០,៦% (៦,៤% ធៀបមួយឆ្នាំមុន) មក ១៩៥,៤លានដុល្លារ។ វិនិយោគក្នុងផ្នែកកាត់ដេរធ្លាក់ ២៨,៤% (២១,៤% ធៀបមួយឆ្នាំមុន) មក ១០៩,៥លានដុល្លារ។ ផ្នែកសណ្ឋាគារ និងអាជីវកម្មទាក់ទងនឹងទេសចរណ៍មានសកម្មភាពខ្លាំង ប៉ុន្តែមិនទទួលបានវិនិយោគទេក្នុងត្រីមាសទី១ នេះ។ ទោះយ៉ាងណា កម្ពុជាបន្តទាក់ទាញ ភ្ញៀវទេសចរបានច្រើនដោយកើន ១៦,៤% (១៧,៨% ធៀបនឹងមួយឆ្នាំមុន) ក្នុងនេះភ្ញៀវមកដល់តាមផ្លូវអាកាសកើន ២២,១% (១៩,០% ធៀបមួយឆ្នាំមុន) ហើយតាមផ្លូវគោកនិងផ្លូវទឹកកើន ១០,៨% (១៦,៥% ធៀបមួយឆ្នាំមុន)។

វិស័យសំណង់ជា សសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ចដែលទទួលរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសាកល ហើយការរើបឡើងវិញ មានល្បឿនយឺត។ តម្លៃសរុបនៃគម្រោងសាងសង់នៅត្រីមាសទី៤ ឆ្នាំ២០១២ ធ្លាក់ ៦៥,៨% ធៀបនឹងត្រីមាសមុន (៥៩,៧% ធៀបមួយឆ្នាំមុន) មក ៥៩,៩លានដុល្លារ។ គម្រោងសាងសង់ផ្ទះនិងភូមិគ្រឹះ ធ្លាក់ ៥៣,៦% (៨៦% ធៀបនឹងមួយឆ្នាំមុន) មក ៨,៥ លានដុល្លារ ហើយគម្រោងផ្ទះល្វែងធ្លាក់ចុះ ៨៣,៤% (៨២,៦% ធៀបនឹងមួយឆ្នាំមុន) មក ១០,២លានដុល្លារ។

ការនាំចេញក៏ធ្លាក់ល្បឿនដែរ។ នៅត្រីមាសទី១ ឆ្នាំ២០១៣ ការនាំចេញសរុបធ្លាក់ ៥៩,៨% ធៀបនឹងត្រីមាសមុន (៥៤,៣% ធៀបមួយឆ្នាំមុន) មក ៥៨៥,៣លានដុល្លារ។ ការនាំចេញសម្លៀកបំពាក់រួមចំណែក ៧៩,០% ក្នុងតម្លៃនាំចេញសរុប ដោយវាធ្លាក់ ៥៩,៥% (៥៦,៨% ធៀបមួយឆ្នាំមុន) មក ៤៦២,៥លានដុល្លារ ក្នុងនេះការនាំចេញទៅUS មាន ៤៣,១%, ទៅEU ៣៣,៧%, ទៅតំបន់អាស៊ាន ១,០% និងទៅជប៉ុន ១៨,១%។ ការនាំចេញផលិតផលកសិកម្ម ដែលមាន កៅស៊ូ និងអង្ករ ធ្លាក់ ៥៦,៩% (៤១,៧% ធៀបមួយឆ្នាំមុន) មក ៤៦,៩លានដុល្លារ។ នៅត្រីមាសទី១ នេះដែរ ការនាំចូលសរុបកើន ១៣,១% (៣៦,២% ធៀបមួយឆ្នាំមុន) ដល់ ២,២ពាន់លានដុល្លារ។ ការនាំចូលសាំងកើន ០,១% (១១,៦% ធៀបមួយឆ្នាំមុន) រីឯការនាំចូលម៉ាស៊ូតធ្លាក់ ០,៦% (០,៣% ធៀបមួយឆ្នាំមុន) ហើយការនាំចូលសម្ភារៈសំណង់ធ្លាក់ ២០,៥% (២,២% ធៀបមួយឆ្នាំមុន)។

## ហិរញ្ញវត្ថុសាធារណៈ

កំណើនធនធានហិរញ្ញវត្ថុ ឆ្លងតាម ការពង្រឹងសកម្មភាពប្រមូលចំណូល នៅតែជាលក្ខខណ្ឌចាំបាច់មួយសម្រាប់រដ្ឋាភិបាល និងសេដ្ឋកិច្ច។ សញ្ញាមួយបង្ហាញពីការរីកចម្រើន គឺកំណើនចំណូលរដ្ឋាភិបាលពីមួយឆ្នាំទៅមួយឆ្នាំ ពិសេសចំណូលចរន្ត។ នៅត្រីមាសទី១ ឆ្នាំ២០១៣ ចំណូលសរុបធ្លាក់ ៩,៨% ធៀបនឹងត្រីមាសមុន (៥,៣% ធៀបមួយឆ្នាំមុន) មក ១៨២០,២ពាន់លានរៀល។ ចំណូលចរន្តធ្លាក់ ៩,០% (៥,១% ធៀបមួយឆ្នាំមុន) ហើយចំណូលពន្ធធ្លាក់ ៤,៤% (១២,២% ធៀបមួយឆ្នាំមុន)។ ចំណូលពន្ធក្នុងស្រុកធ្លាក់ ១,៩% (កើន ១៤,៧% ធៀបមួយឆ្នាំមុន) មក ១២៥៣,១ពាន់លានរៀល។ ចំណូលមិនមែនពន្ធធ្លាក់ ៣០,៦% (២៧,៨% ធៀបមួយឆ្នាំមុន) មក ២៣៩ពាន់លានរៀល។ ចំណូលមូលធនធ្លាក់ ៧៥,៣% (៨៧,៤% ធៀបមួយឆ្នាំមុន) មក ៥,៩ពាន់លានរៀល។ កិច្ចប្រឹងប្រែងកាត់បន្ថយការខ្ជះខ្ជាយក្នុងចំណាយរដ្ឋាភិបាល ក៏អាចសង្កេតឃើញតាមការថយចុះចំណាយរដ្ឋាភិបាលក្នុងត្រីមាសទី១។ ប៉ុន្តែការថយចុះចំណាយសាធារណៈ អាចមានឥទ្ធិពលអវិជ្ជមានលើសេដ្ឋកិច្ច ប្រសិនបើមានកាត់បន្ថយចំណាយលើកម្មវិធីសង្គមសំខាន់ៗ។ ចំណាយសរុបធ្លាក់ ៦៦,៣% ធៀបនឹងត្រីមាសមុន (៤៥,២% ធៀបមួយឆ្នាំមុន) មក ៩២៥,៩ពាន់លានរៀល។ ចំណាយមូលធនធ្លាក់ ៨៥,៦% (៧៩,១% ធៀបមួយឆ្នាំមុន រីឯចំណាយលើបៀវត្សរ៍ធ្លាក់ ៣៣,៦% (២២,៣% ធៀបមួយឆ្នាំមុន)។ ចំណាយឧបត្ថម្ភធន និងជំនួយសង្គមធ្លាក់ ៤១,២% (កើន ៣០,៥% ធៀបមួយឆ្នាំមុន) មក ២៤៧ពាន់លានរៀល។

## អតិផរណា និង អត្រាប្តូរប្រាក់

នៅត្រីមាសទី១ អតិផរណាត្រូវបានគ្រប់គ្រងយ៉ាងល្អ ដោយធ្លាក់ចុះមកត្រឹម១,៥%ធៀបនឹង១,៨%នៅត្រីមាសមុននិង២,៩%កាលពីមួយឆ្នាំមុន។សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈគ្មានជាតិស្រាកើន ១,៧% ធៀបនឹង ៣,៤% កាលពីមួយឆ្នាំមុន។ នៅត្រីមាសទី១ នេះដែរ ប្រាក់រៀលឡើងថ្លៃ ០,០២% ធៀបនឹងត្រីមាសមុន (១,៣% ធៀបមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ។ មាសធ្លាក់ថ្លៃ ៣,២% (២,១% ធៀបមួយឆ្នាំមុន) មកត្រឹម ១៩៩,៨ដុល្លារ/ជី។ ម៉ាស៊ូតឡើងថ្លៃ ០,១% (ធ្លាក់ថ្លៃ ១,២% ធៀបមួយឆ្នាំមុន) ដល់ ៥១៣៤,៤រៀល/លីត្រ។ សាំងឡើងថ្លៃ ២,២% (០,៣% ធៀបមួយឆ្នាំមុន) ដល់ ៥៤១០,៥រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៤ ឆ្នាំ២០១២ រូបិយវត្ថុទូទៅសរុបកើន ២០,៩% ធៀបនឹងមួយឆ្នាំមុន ដល់ ២៨.៥៩១,៦ពាន់លានរៀល, រូបិយវត្ថុ

[1] អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

(M1) កើន ២,៣% ហើយរូបិយវត្ថុផ្សេងៗកើន ៤៤,៦%។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធកើន ២៤,៣% ធៀបនឹងត្រីមាសមុន (៨១,២% ធៀបមួយឆ្នាំមុន) ក្នុងនោះឥណទេយ្យលើរដ្ឋាភិបាលសុទ្ធកើន ១,៩% (១៧,១% ធៀបមួយឆ្នាំមុន) ហើយឥណទានសម្រាប់វិស័យឯកជនកើន ១០% (៣៤,១% ធៀបមួយឆ្នាំមុន) ដែលបង្ហាញពីកំណើនការផ្តល់ប្រាក់កម្ចីទៅឲ្យក្រុមហ៊ុនឯកជន។

## ស្ថានភាពក្រីក្រ

ការលក់ពលកម្ម និងការរកចំណូលពីរបរលក់ដូរតូចតាច ជាប្រភពចំណូលចម្បង សម្រាប់ពលករងាយរងគ្រោះទាំងប្រាំបួនក្រុម និងគ្រួសារពួកគេ។ នៅខែឧសភា ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នករត់ម៉ូតូឌុប បានធ្លាក់ចុះ រីឯក្រុមផ្សេងទៀតរកចំណូលបានច្រើនជាងមុន។

អ្នកស៊ីឈ្នួលធ្វើស្រែរកចំណូលបាន ៦៤២៧រៀល/ថ្ងៃ ឬធ្លាក់ចុះ ០,១% ធៀបនឹងមួយឆ្នាំមុន ប៉ុន្តែកើន ១១% បើធៀបនឹងកាលពីខែកុម្ភៈ ដោយសារពលករក្រុមនេះថយចំនួន ដូច្នេះអាចទារកម្រៃបានខ្ពស់ជាងមុន។ ជាមធ្យម ពួកគេចំណាយអស់ ៤១១៨រៀល/ថ្ងៃ ក្នុងនេះ ៨៥% ជាចំណាយលើអាហារ។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ ១៣% ធៀបនឹងបីខែមុន (៨,០% ធៀបមួយឆ្នាំមុន) មក ១២.៥២២រៀល។ អ្នកឆ្លើយសម្ភាសន៍ ៥០% ស្នាក់នៅផ្ទះជួលក្នុងក្រុងភ្នំពេញ ដោយផ្ទះនីមួយៗមានមនុស្សស្នាក់នៅជាមធ្យមបីនាក់។ ក្នុងចំណាយប្រចាំថ្ងៃរបស់ពួកគេ ចំណាយឈ្នួលផ្ទះ មានត្រឹម ១,៣% រីឯចំណាយលើម្ហូបអាហារមាន ៩៥%។ ប្រាក់ចំណូលនេះ ពួកគាត់អាចចិញ្ចឹមគ្រួសារបាន លុះត្រាតែសមាជិក មានការងារធ្វើដែរ។

ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើនលឿនណាស់ រហូតដល់១០.៤៤០រៀលឬកើន២៦%ធៀបនឹងឆ្នាំមុននិង១០% ធៀបនឹងបីខែមុន។ មានមនុស្សកាន់តែច្រើនបានចូលធ្វើការនេះ ប៉ុន្តែពួកអ្នកឆ្លើយសម្ភាសន៍ នៅតែរកចំណូលបានច្រើនជាងមុន ព្រោះស្គាល់កន្លែងរើសអេតចាយយ៉ាងច្បាស់។ ពួកគេត្រូវធ្វើដំណើរទៅកន្លែងរើសអេតចាយ ធ្វើឲ្យចំណាយដឹកជញ្ជូនឡើងខ្ពស់ដល់លំដាប់ទី២ បន្ទាប់ពីចំណាយលើម្ហូបអាហារ។

អ្នកលក់បន្លែតូចតាច រកចំណូលបានជាមធ្យម ១១.៥៧១ រៀល/ថ្ងៃ ឬកើន ១៦% ធៀបនឹងខែកុម្ភៈ។ អ្នកឆ្លើយសម្ភាសន៍ ៨៥% ជាអ្នកមកពីខេត្ត និងមាន ៤៧% ត្រូវធ្វើដំណើរទៅលក់ដូរ និងត្រឡប់មកផ្ទះវិញជារៀងរាល់ថ្ងៃ។ ក្នុងចំណាយប្រចាំថ្ងៃ ភាគច្រើនជាម្ហូបអាហារ និងការធ្វើដំណើរ។ អ្នកលក់បន្លែតូចតាចតែងស្វែងរកប្រាក់កម្ចី ឬឲ្យសមាជិកគ្រួសារខ្លះទៀតទៅធ្វើការ ប្រសិនបើចំណូលរបស់គាត់មិនអាចផ្គត់ផ្គង់គ្រួសារបាន។

ចំណូលប្រចាំថ្ងៃរបស់ កម្មករសំណង់មានជំនាញធ្លាក់ចុះ ៦,៧% ធៀបនឹងខែកុម្ភៈ មកត្រឹម ១៤.១៣៦រៀល រីឯចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញកើន ៩,៤% ដល់ ១៣.៧២៥រៀល។ បន្ទាប់ពីម្ហូបអាហារ ចំណាយធំទី២ សម្រាប់កម្មករសំណង់មានជំនាញ គឺការដឹកជញ្ជូន រីឯសម្រាប់កម្មករសំណង់គ្មានជំនាញ គឺឈ្នួលផ្ទះ។ កម្មករសំណង់មានជំនាញ អាចសន្សំប្រាក់បានច្រើនជាង កម្មករសំណង់គ្មានជំនាញ។

ចំណូលប្រចាំថ្ងៃរបស់អ្នកបម្រើតាមភោជនីយដ្ឋានកើន ៣,៣% ធៀបនឹងបីខែមុន ដោយសារជាសំខាន់ កំណើនអតិថិជន។ មានអ្នកឆ្លើយសម្ភាសន៍តែ ១៥% ប៉ុណ្ណោះ ដែលអាចសន្សំប្រាក់សម្រាប់ថ្ងៃអនាគត។ ក្រុមនេះតែងទទួលបានកន្លែងស្នាក់នៅពីម្ចាស់ហាង ដែលជាការសន្សំសំចៃមួយយ៉ាងធំ។ អ្នកលីសែងរកបាន ១២.៨២៣រៀល/ថ្ងៃ ឬ កើន ០,៦% ធៀបនឹងបីខែមុន។ ពួកគេចំណាយជាមធ្យម ១០.០៧០រៀល/ថ្ងៃ និងជាសំខាន់ទៅលើម្ហូបអាហារ និងការដឹកជញ្ជូន។ ចំណូលរបស់អ្នកធាក់ស៊ីក្លូកើន ១១% ធៀបនឹងបីខែមុន។

ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរធ្លាក់ចុះ ២,២% ធៀបនឹងខែកុម្ភៈ មកត្រឹម ៩៧៧៦៛។ អ្នកឆ្លើយសម្ភាសន៍ ៥៥% ធ្វើការផ្នែកដេរ។ ជាមធ្យម កម្មករកាត់ដេរធ្វើការ ៥៨ម៉ោង/សប្តាហ៍ ហើយរំពឹងចង់បានការងារក្រៅម៉ោងបន្ថែម ដើម្បីរកប្រាក់បានច្រើន។ ពួកគេអាចផ្ញើប្រាក់ខ្លះទៅឲ្យអ្នកផ្ទះ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិតឡើយ។ ទោះយ៉ាងនេះក្តី ពួកគេមិនចង់ប្តូរការងារទេ ព្រោះគ្មានជំនាញអ្វីផ្សេងក្រៅពីការកាត់ដេរនេះ៕

តពីទំព័រ ១៤ **កំណែទម្រង់វិស័យជលផល...**

ជីវភាពរស់នៅ និងដល់សន្តិសុខស្បៀងរបស់ប្រជាជនរាប់លាននាក់។ ដោយសារបឹងទន្លេសាបមានសារៈសំខាន់ ចំពោះសេដ្ឋកិច្ចនៅជនបទ ការគ្រប់គ្រងបឹងទន្លេសាបប្រកបដោយចីរភាព គឺជាការសំខាន់ណាស់ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់គ្រួសារក្រីក្រ និងចូលរួមចំណែកពង្រឹងស្ថិរភាពសង្គម។ កំណែទម្រង់វិស័យជលផលបានផ្តល់នូវឱកាសជាច្រើន សម្រាប់ការពង្រីកអត្ថប្រយោជន៍ទាំងនេះ ប៉ុន្តែវាទាមទារឲ្យមានកិច្ចសហការគ្នាយូរអង្វែង រវាងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីស្វែងរកនូវគំនិតច្នៃប្រឌិតថ្មីៗសម្រាប់ការគ្រប់គ្រងផ្នែកស្ថាប័ន ដើម្បីវាយតម្លៃ និងរៀនសូត្រពីបទពិសោធន៍ទាំងនោះ និងដើម្បីយកវាមកធ្វើការកែសម្រួល និងធ្វើបច្ចុប្បន្នភាព ដោយយោងទៅលើបទពិសោធន៍ដែលរៀនសូត្របាន៕

**Suggested Reading**

Kurien, John, So Nam and Mao Sam Onn (2006), “Cambodia’s Aquarian Reforms: The Emerging Challenges for Policy and Research” (Phnom Penh: Inland Fisheries Research and Development Institute, Fisheries Administration)

Ratner, Blake (2011), “Common-Pool Resources, Livelihoods, and Resilience-Critical Challenges for Governance in Cambodia”, IFPRI Discussion Paper 01149 (Penang: WorldFish)

Ratner, Blake (2006), “Community Management by Decree? Lessons from Cambodia’s Fisheries Reform”, Society and Natural Resources, 19, pp.79-86

Ratner, Blake, Guy Halpern and Mam Kosal (2012), *Catalyzing Collective Action to Address Natural Resource Conflict: Lessons from Cambodia’s Tonle Sap Lake,* CAPRi Working Paper No.103 (Washington, D.C.: International Food Policy Research Institute) http://dx.doi.org/10.2499/CAPRiWP103

WorldFish (forthcoming), “After the Reforms: Strengthening Governance of Tonle Sap Aquatic Resources”(Phnom Penh: WorldFish)

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៨-១៣*

| | 2008 | 2009 | 2010 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 92.0 | 615.0 | 530.68 | 4.1 | 156.4 | 123.9 | 440.6 | 154.7 | 81.2 | 181.1 | 114.6 | 2.3 |
| ឧស្សាហកម្ម | 724.9 | 818.5 | 403.66 | 67.1 | 257.1 | 2361.0 | 174.9 | 208.7 | 173.7 | 245.6 | 196.5 | 195.4 |
| *កាត់ដេរ* | *142.8* | *90.1* | *122.81* | *57.1* | *108.4* | *109.7* | *118.7* | *139.4* | *97.5* | *107.2* | *152.9* | *109.5* |
| សេវាកម្ម | 10,003.2 | 4432.0 | 1337.34 | 209.5 | 2229.2 | 264.1 | 722.6 | 50.9 | 18.0 | 2.1 | 845.6 | 21.2 |
| *សណ្ឋាគារ និងទេសចរណ៍* | *8758.1* | *3980.1* | *1105.14* | *107.9* | *2221.9* | *264.1* | *257.0* | *50.9* | *0.0* | *0.0* | *640.6* | *0.0* |
| សរុប | 10,570.9 | 5865.5 | 2271.7 | 280.7 | 2642.7 | 2748.9 | 1338.1 | 414.4 | 273.0 | 428.8 | 1156.6 | 218.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | -77 | 8.41 | -4 | -51.3 | -69 | -33.9 | 55.6 | 169.8 | -81.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 308.6 | -44.5 | -61.3 | -42.2 | 643.2 | 753 | 9.6 | 48.4 | -89.6 | -84.4 | -13.6 | -47.5 |

*Including expansion project approvals. Source: Cambodian Investment Board

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៨-១២

| | 2008 | 2009 | 2010 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 154.7 | 64.3 | 36.2 | 4.1 | 5.9 | 106.3 | 60.9 | 64.8 | 66.6 | 18.3 | 8.5 |
| ផ្ទះល្វែង | 221.6 | 149.6 | 183.8 | 16.1 | 22.8 | 90.0 | 58.5 | 60.8 | 219.3 | 61.6 | 10.2 |
| ផ្សេងៗ | 740.9 | 227.3 | 269.7 | 23.6 | 48.7 | 51.1 | 29.3 | 197.2 | 47.8 | 94.9 | 41.2 |
| សរុប | 1117.0 | 441.2 | 489.8 | 43.8 | 77.4 | 247.4 | 148.7 | 322.8 | 333.6 | 174.9 | 59.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | |
| សរុប | - | - | - | -58.7 | 76.7 | 219.7 | -39.9 | 117.1 | 3.3 | -47.6 | -65.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | |
| សរុប | 75.7 | -60.5 | 11 | -14.8 | -61.7 | 215.6 | 40.29 | 637.1 | 331.1 | -29.3 | -59.7 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៨-១៣

| | 2008 | 2009 | 2010 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1239.4 | 1111.7 | 1304.3 | 227.4 | 286.9 | 335.3 | 430.7 | 513.6 | 317.1 | 370.5 | 500.7 | 611.2 |
| តាមផ្លូវគោក និងទឹក | 881.9 | 999.7 | 1094.6 | 351.0 | 319.6 | 364.5 | 366.3 | 481.5 | 424.3 | 450.3 | 506.1 | 560.9 |
| សរុប | 2121.3 | 2111.5 | 2398.9 | 778.4 | 606.5 | 699.8 | 797.1 | 995.2 | 761.4 | 820.9 | 1006.8 | 1172.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | 10.4 | -22.1 | 15.4 | 13.9 | 24.9 | -23.5 | 7.8 | 22.6 | 16.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 5.3 | 0.5 | 13.6 | 13.9 | 12.8 | 20.2 | 13.0 | 27.8 | 25.5 | 17.3 | 26.3 | 17.8 |

Source: Ministry of Tourism

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៨-១៣*

| | 2008 | 2009 | 2010 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3097.8 | 2901.6 | 3630.2 | 1017.6 | 1132 | 1455.6 | 1324.2 | 1280.1 | 1775.9 | 1595.8 | 1454.7 | 585.3 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2986.2 | 2565.3 | 3223.4 | 880.5 | 964.15 | 1285.7 | 1129.23 | 1070.8 | 1474.7 | 1329.1 | 1140.83 | 462.5 |
| *- សហរដ្ឋអាមេរិក* | 1908.3 | 1512.6 | 1853.9 | 464.5 | 466.7 | 619.4 | 504.71 | 493.3 | 627.3 | 566.6 | 456.07 | 199.3 |
| *- សហភាពអឺរ៉ុប* | 689.0 | 644.7 | 809.5 | 232.0 | 301.4 | 397.5 | 391.3 | 328.4 | 504.1 | 462.7 | 421.82 | 156.0 |
| *- អាស៊ាន* | 10.76 | 6.9 | 9.9 | 3.8 | 4.18 | 4.7 | 4.95 | 6.4 | 11.7 | 11.4 | 9.76 | 4.7 |
| *- ជប៉ុន* | 25.2 | 44.5 | 86.5 | 34.3 | 28 | 43.4 | 41.25 | 50.1 | 48.9 | 47.1 | 42.47 | 18.8 |
| *- ប្រទេសផ្សេងៗ* | 352.9 | 356.5 | 463.6 | 145.9 | 163.89 | 220.7 | 187.03 | 192.5 | 282.7 | 241.3 | 210.71 | 83.8 |
| កសិកម្ម | 44.5 | 73.1 | 164.9 | 74.0 | 97.07 | 98.9 | 92.06 | 80.5 | 101.3 | 86.1 | 108.77 | 46.9 |
| *- កៅស៊ូ* | 35.8 | 51.6 | 89.1 | 49.9 | 48.6 | 56.1 | 43.06 | 40.3 | 46.4 | 46.1 | 43.84 | 20.2 |
| *- ឈើ* | 3.4 | 3.5 | 34.1 | 6.2 | 16.8 | 16.1 | 9.7 | 8.9 | 12.4 | 4.1 | 11.6 | 0.1 |
| *- ត្រី* | 2.3 | 3.9 | 2.8 | 0.6 | 0.4 | 1.4 | 0.7 | 0.5 | 0.7 | 0.4 | 0.4 | 0.1 |
| *- ស្រូវ* | 2.6 | 10.9 | 34.7 | 16.9 | 30.3 | 22.4 | 37.0 | 27.1 | 37.5 | 31.7 | 50.2 | 22.4 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 0.5 | 3.0 | 4.1 | 0.5 | 1.0 | 2.9 | 1.6 | 3.9 | 4.4 | 3.9 | 2.8 | 4.1 |
| ផ្សេងៗ | 67.1 | 263.22 | 242.0 | 63.2 | 70.8 | 71.0 | 102.9 | 128.8 | 199.9 | 180.6 | 205.1 | 76.0 |
| ការនាំចូលសរុប | 4272.5 | 4331.5 | 5190.6 | 1454.9 | 1690.1 | 1519.1 | 1711.9 | 1609.2 | 1885.4 | 2015.2 | 1938.2 | 2192.1 |
| ក្នុងនេះ៖ សាំង | 84.8 | 91.13 | 108.6 | 62.2 | 76.7 | 73.8 | 81.8 | 70.7 | 76.7 | 78.0 | 78.8 | 78.9 |
| ម៉ាស៊ីន | 19.5 | 180.67 | 203.8 | 92.7 | 129.9 | 118.9 | 105.5 | 139.4 | 126.6 | 138.3 | 139.9 | 139.0 |
| សម្ភារៈសំណង់ | 56.3 | 49.74 | 57.6 | 18.8 | 12.7 | 11.6 | 12.0 | 13.5 | 14.1 | 16.5 | 16.6 | 13.2 |
| ផ្សេងៗ | 4011.8 | 4010 | 4820.6 | 1288 | 1471 | 1315 | 1513 | 1386 | 1668.0 | 1782.4 | 1703.0 | 1961.1 |
| ជញ្ជីងពាណិជ្ជកម្ម | -1174.7 | -1429.9 | -1560.5 | -437.2 | -558.1 | -63.5 | -387.6 | -329.1 | -642.2 | -419.4 | -483.6 | -1606.68 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | *-6.6* | 9.5 | 33.4 | -12.2 | -5.2 | -37.7 | -9.9 | -14.2 | -59.5 |
| ការនាំចេញសរុប | - | - | - | *-4.9* | 11.2 | 28.6 | -9.0 | -3.3 | 38.7 | -10.1 | -8.8 | -59.8 |
| ការនាំចូលសរុប | - | - | - | *-8.9* | 6.2 | -10.1 | 12.7 | -6.0 | 17.2 | 6.9 | -3.8 | 13.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 1.6 | -14.1 | 25.7 | 40.8 | 34.5 | 37.0 | 19.8 | 21.6 | 53.0 | 3.4 | 1.0 | -56.8 |
| ការនាំចេញសរុប | 1.6 | -6.3 | 25.1 | 46.7 | 37.9 | 39.3 | 23.7 | 25.8 | 56.9 | 9.6 | 9.9 | -54.3 |
| ការនាំចូលសរុប | 1.3 | 1.4 | 19.8 | 30.1 | 33.7 | 3.2 | 28.1 | 10.6 | 11.6 | 32.7 | 13.2 | 36.2 |

*Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (web site)

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៨-១៣ (ពាន់លានរៀល)

| | 2008 | 2009 | 2010 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 5290.0 | 5988.99 | 2805.83 | 1000.5 | 1564.25 | 1510.1 | 1776.61 | 1728.9 | 2045.1 | 1900.8 | 2017.0 | 1820.2 |
| ចំណូលចរន្ត | 5210.7 | 5859.08 | 2786.12 | 1378.6 | 1563.01 | 1497.59 | 1740.12 | 1725.8 | 1928.6 | 1796.4 | 1993.1 | 1814.3 |
| ចំណូលពន្ធ | 4409.9 | 4692.96 | 2457.02 | 1142.3 | 1367.52 | 1313.35 | 1454.33 | 1403.82 | 1721.8 | 1560.7 | 1648.5 | 1575.3 |
| ពន្ធក្នុងស្រុក | 3248.4 | 3533.57 | 1727.10 | 875.6 | 1095.26 | 996.642 | 1104.12 | 1092.27 | 1403.4 | 1230.0 | 1277.2 | 1253.1 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1161.5 | 1159.39 | 639.00 | 266.7 | 272.27 | 316.709 | 350.207 | 311.253 | 318.4 | 330.7 | 371.4 | 322.3 |
| ចំណូលមិនមែនពន្ធ | 800.8 | 1166.13 | 507.13 | 236.3 | 195.48 | 184.23 | 285.8 | 330.98 | 206.9 | 235.7 | 344.6 | 239.0 |
| ចំណូលលើទ្រព្យសម្បត្តិ | 78.0 | 291.13 | 4.87 | 10.6 | 18.64 | 15.19 | 19.35 | 91.28 | 13.1 | 22.5 | 16.2 | 8.2 |
| លក់ទំនិញ និងសេវា | 424.7 | 460.07 | 268.08 | 130.0 | 138.92 | 144.192 | 175.627 | 166.899 | 171.4 | 132.8 | 196.3 | 152.8 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.2 | 408.91 | 391.70 | 95.7 | 37.9 | 24.856 | 90.815 | 63.8 | 22.4 | 80.5 | 132.1 | 78.0 |
| ចំណូលជាមូលធន | 79.3 | 129.92 | 2019.39 | 21.9 | 1.25 | 12.513 | 36.486 | 3.148 | 116.4 | 104.4 | 23.9 | 5.9 |
| ចំណាយសរុប | 6297.8 | 8784.65 | 4259.67 | 1581.6 | 2025.15 | 2310.61 | 3115.05 | 1688.33 | 2425.6 | 2951.3 | 2751.5 | 925.9 |
| ចំណាយជាមូលធន | 2574.4 | 2853.23 | 1495.19 | 579.8 | 721.01 | 801.167 | 1444.89 | 699.937 | 716.2 | 1194.5 | 1017.7 | 146.3 |
| ចំណាយចរន្ត | 3809.0 | 4773.07 | 2848.81 | 857.5 | 1304.13 | 1509.44 | 1670.15 | 988.398 | 1709.4 | 1756.7 | 1733.9 | 879.6 |
| បៀវត្សរ៍ | 1397.0 | 2048.81 | 1208.81 | 401.0 | 531.6 | 629.697 | 608.253 | 508.919 | 725.2 | 657.5 | 595.0 | 395.3 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 927.1 | 1099.42 | 613.31 | 257.4 | 450.85 | 323.282 | 487.345 | 189.594 | 514.6 | 462.1 | 420.5 | 247.4 |
| ចំណាយចរន្តផ្សេងទៀត | 1384.9 | 1624.84 | 1067.07 | 199.1 | 321.7 | 556.5 | 574.6 | 289.9 | 469.7 | 637.1 | 718.4 | 236.9 |
| សមតុល្យជាទូទៅ | -1007.8 | -2795.66 | -1453.83 | -181.2 | -460.9 | -800.5 | -1,338.4 | 196.5 | -380.6 | -1050.5 | -734.5 | 0.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2055.10 | 1845.21 | 772.81 | 544.4 | 576.9 | 272.9 | 985.0 | 577.8 | 491.5 | 959.3 | 429.2 | 894.4 |
| ហិរញ្ញប្បទានក្នុងស្រុក | -127.00 | 938.64 | 567.96 | -2718.5 | 238.7 | 312.5 | 105.6 | -565.7 | 148.4 | 22.1 | 62.4 | -44.2 |

Source: MEF web site

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៨-១៣

| | 2008 | 2009 | 2010 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 19.7 | -0.7 | 4.1 | 3.6 | 6.3 | 6.7 | 4.9 | 2.9 | 2.9 | 1.6 | 1.8 | 1.5 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 33.1 | -0.3 | 4.4 | 3.7 | 7.6 | 8.2 | 6.2 | 3.4 | 3.4 | 1.3 | 1.4 | 1.7 |
| - ដឹកជញ្ជូន | 19.4 | -10.7 | 7.0 | 5.0 | 7.3 | 8.8 | 6.3 | 3.0 | 3.0 | 1.1 | 1.2 | -0.8 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4058.2 | 4140.5 | 4187.1 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.7 | 3995.9 | 3995 |
| រៀលក្នុង ១ បាតថៃ | 123.5 | 121.1 | 133.13 | 132.7 | 133.8 | 135.2 | 131.1 | 130.2 | 129.0 | 129.3 | 131.3 | 134.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.8 | 23.4 | 21.725 | 19.9 | 19.6 | 19.8 | 19.4 | 19.3 | 19.4 | 19.5 | 19.2 | 19.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 105.9 | 113.1 | 147.58 | 147.9 | 181.5 | 204.6 | 203.8 | 204.1 | 194.5 | 198.3 | 206.5 | 199.8 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4555.2 | 3170.9 | 3859.3 | 4427.2 | 4784.6 | 4924.5 | 4908.3 | 5193.9 | 4458.3 | 4983.9 | 5128.8 | 5134.4 |
| ថ្លៃសាំង (រៀល/លីត្រ) | 4750.8 | 3593.1 | 4368.1 | 4750.1 | 5065.5 | 5248.4 | 5113.8 | 5395.8 | 5308.3 | 5251.3 | 5295.4 | 5410.5 |

Sources: NIS, NBC and CDRI

### តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៧-១២ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 Q1 | Q2 | Q3 | Q4 | 2012 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17079.1 | 18,099.9 | 17,695.2 | 17,893.9 | 18,652.3 | 18,729.6 | 18,463.8 | 18,154.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 576.0 | 1513.3 | 1573.0 | 2778.9 | | 3907.7 | 4961.6 | 5760.8 | 6211.2 | 7922.3 | 8400.3 | 10437.4 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -1816.0 | -2987.0 | -2252.0 | -2126.6 | -2252.7 | -2184.2 | -1925.8 | -2123.1 | -2542.4 | -2399.9 | -2440.6 | -2486.4 |
| ឥណទានដល់ផ្នែកឯកជន | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 13,909 | 15,290.6 | 16,385.7 | 17,552.8 | 18,789.0 | 20,081.4 | 21,398.2 | 23,536.6 |
| រូបិយវត្ថុទូទៅ M2 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 20,278.3 | 22,007.6 | 22,656.8 | 23,654.7 | 24,863.5 | 26,651.9 | 26,864.1 | 28,591.9 |
| រូបិយវត្ថុ M1 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3497.2 | 3539.8 | 3681.3 | 3956.2 | 3984.6 | 3871.8 | 3818.2 | 4045.7 |
| រូបិយវត្ថុផ្សេងៗ | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 16,781.1 | 18,467.8 | 18,975.5 | 19,698.5 | 20,878.9 | 22,780.1 | 23,046.0 | 24,546.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 62.9 | 4.8 | 36.9 | 20.0 | 17.7 | 20.5 | 20.0 | 21.5 | 20.2 | 21.1 | 18.6 | 20.9 |
| រូបិយវត្ថុ M1 | 23.8 | 16.9 | 30.1 | 3.2 | 11.1 | 13.6 | 20.2 | 22.8 | 11.4 | 9.4 | 3.7 | 2.3 |
| រូបិយវត្ថុផ្សេងៗ | 75.2 | 2.2 | 38.6 | 24.0 | 19.1 | 21.9 | 19.9 | 21.2 | 22.0 | 23.4 | 21.5 | 44.6 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 ឧសភា | សីហា | វិច្ឆិកា | 2013 កុម្ភៈ | ឧសភា | 2012 វិច្ឆិកា | 2013 កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 12,628 | 8091 | 9055 | 9532 | 10,686 | 10690 | 10454 | 9588 | 10,681 | 12.5 | 2.2 | 0.0 |
| អ្នកលីសែង | 9005 | 9549 | 9964 | 10,785 | 12,713 | 12,479 | 12,574 | 12744 | 12,823 | 9.4 | 18.0 | 0.9 |
| អ្នកលក់បន្លែតូចតាច | 9926 | 8273 | 8266 | 8337 | 9901 | 10,347 | 10,542 | 9949 | 11,571 | 49.0 | -19.1 | 16.9 |
| អ្នករើសអេតចាយ | 4652 | 5857 | 6698 | 8388 | 8266 | 9139 | 9328 | 9483 | 10,440 | -9.3 | 18.7 | 26.3 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4327 | 4646 | 5607 | 5986 | 6261 | 5569 | 6436 | 6527 | 6744 | 3.2 | 5.6 | 7.7 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8697 | 6197 | 5691 | 5695 | 6431 | 8483 | 5000 | 5828 | 6427 | 9.9 | 23.8 | -0.1 |
| កម្មកររោងចក្រកាត់ដេរ | 6554 | 7085 | 7746 | 8409 | 8391 | 9599 | 8989 | 10,000 | 9776 | 4.7 | 16.9 | 13.6 |
| អ្នករត់ម៉ូតូឌុប | 15,691 | 10,685 | 10,623 | 11,568 | 13,616 | 12,807 | 13,042 | 14,427 | 12,522 | 1.1 | 17.7 | -8.0 |
| កម្មករសំណង់គ្មានជំនាញ | 8779 | 8343 | 8790 | 10,307 | 11,589 | 10,690 | 11,375 | 12,548 | 13,728 | 15.4 | 17.7 | 18.5 |
| កម្មករសំណង់មានជំនាញ | 12,710 | 12,487 | 11,952 | 13,159 | 12,847 | 14,029 | 14,270 | 15,156 | 14,136 | -4.4 | 9.6 | 10.0 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗ...**

ពីរថ្ងៃនៅគណៈកម្មការអឺរ៉ុបនៅក្រុង Brussels ស្ដីពីតួនាទីនៃអាជ្ញាធរមូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិឲ្យមានចីរភាពនិងសមធម៌ ដោយផ្ដោតលើឧស្សាហកម្មយកប្រេងកាត និងរ៉ែ, កិច្ចប្រជុំប្រចាំឆ្នាំនៃបណ្ដាញអភិវឌ្ឍន៍អាស៊ីបូព៌ា (EADN) និងបណ្ដាញអភិវឌ្ឍន៍សាកលជាប់ពាក់ព័ន្ធ នៅក្រុងម៉ានីល ដែលសហការរៀបចំឡើងដោយធនាគារពិភពលោក និងវិទ្យាស្ថានហ្វីលីពីនសម្រាប់ការសិក្សាអភិវឌ្ឍន៍ ហើយក្នុងនោះលោកបានធ្វើបទបង្ហាញមួយស្ដីពី ការវាយតម្លៃពីកំណើនសម្រាប់គ្រប់គ្នានៅបណ្ដាប្រទេសក្នុងមហាអនុតំបន់មេគង្គ, និងបានទៅចូលរួមក្នុងកិច្ចប្រជុំដ៏ជំនាញ រយៈពេលមួយថ្ងៃនៅក្រុងបាងកកស្ដីពី ទីផ្សារ និងការគ្រប់គ្រងថាមពលនៅមីយ៉ាន់ម៉ា ដែលសហការរៀបចំឡើងដោយ វិទ្យាស្ថានស្រាវជ្រាវថាមពលនៃសាកលវិទ្យាល័យ Chulalongkorn, វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា និងសាកលវិទ្យាល័យតូក្យូ។

នៅថ្ងៃទី២៨ មិថុនា CDRI បានធ្វើសិក្ខាសាលាបូកសរុបនៅពាក់កណ្ដាលផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-១៥ ដោយមានការចូលពីអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ និងថ្នាក់កណ្ដាល និងអ្នកស្រាវជ្រាវជាន់ខ្ពស់នានា ដើម្បីវាយតម្លៃពីលទ្ធផលសម្រេចបានចម្បងៗ ធៀបនឹងសូចនាករបច្ចុប្បន្នសម្រាប់វាស់វែងលទ្ធផល, កែតម្រូវគោលដៅ និងសូចនាករកំណត់លទ្ធផលនានា ដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាព និងអាទិភាពថ្មីឬបានប្រែប្រួល ចាប់តាំងពេលបង្កើតផែនការ និងកែតម្រូវសូចនាករកំណត់លទ្ធផល សម្រាប់អនុវត្តក្នុងរយៈពេលនៅសល់នៃផែនការ និងងាយស្រួលវាស់វែង។ លទ្ធផលនៃសិក្ខាសាលានេះ នឹងយកទៅរាយការណ៍ក្នុងការប្រជុំក្រុមប្រឹក្សាភិបាល CDRI នៅខែកក្កដា និងការបូកសរុបពាក់កណ្ដាលអាណត្តិរបស់ Sida នៅចុងឆ្នាំ២០១៣។

នៅចុងខែមិថុនា CDRI បានទទួលដំណឹងដ៏ក្រៀមក្រំពីមរណភាពរបស់សមាជិកក្រុមប្រឹក្សាភិបាលម្នាក់គឺលោកស្រី Dato' Dr Mahani Zainal Abidin ជានាយកប្រតិបត្តិនៃ ISIS Malaysia ជាសេដ្ឋវិទូដ៏ឆ្នើម ជាអ្នកមានឥទ្ធិពលលើគោលនយោបាយ និងជាអ្នកចូលរួមសកម្មក្នុងកិច្ចការអាស៊ាននិងតំបន់។ មរណភាពនេះជាការបាត់បង់មួយដ៏ធំ ហើយ CDRI សូមចូលរួមមរណទុក្ខជាមួយក្រុមគ្រួសារនិងញាតិមិត្ត ISIS Malaysia និងអ្នករួមការងារនានានៅក្នុងតំបន់ ដែលតែងវាយតម្លៃខ្ពស់ចំពោះកម្លាំងប្រាជ្ញា និងកម្លាំងចិត្តរបស់លោកស្រី។

## ផ្នែកស្រាវជ្រាវ

**កម្មវិធី អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ** (DGPSR)

គម្រោងចំនួនប្រាំពីរដែលទទួលបានមូលនិធិជាសំខាន់ពី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិស៊ុយអែត (Sida) កំពុងស្ថិតក្នុងដំណាក់កាលបញ្ចប់។ របាយការណ៍ស្ដីពី "អភិបាលកិច្ចតំបន់ទីក្រុងនៅកម្ពុជាក្រោយធ្វើវិមជ្ឈការ" កំពុងចងក្រងបង្កើយក្រោយទទួលបានការជួយមតិពីទីប្រឹក្សាគម្រោង។ របាយការណ៍ស្ដីពី "វិមជ្ឈការបែបប្រជាធិបតេយ្យ និងយេនឌ័រ៖ ការវិភាគពីយេនឌ័រក្នុងគណបក្សនយោបាយនៅកម្ពុជា" និង "សង្គមស៊ីវិលថ្នាក់ក្រោមជាតិនៅកម្ពុជា៖ ការវិភាគតាមទស្សនៈ Gramsci" កំពុងរៀបចំដើម្បីចេញផ្សាយ។ សម្រាប់គម្រោង "ម្ភៃឆ្នាំបន្ទាប់ពីអាជ្ញាធរអ៊ុនតាក់៖ តើសង្គមស៊ីវិលកម្ពុជាបានរឹងមាំឡើងឬទេ?" ក្រុមស្រាវជ្រាវបានឆ្លើយតបការជួយមតិបានរួចរាល់ ហើយបច្ចុប្បន្នកំពុងបង្កើយរបាយការណ៍សម្រាប់ការចេញផ្សាយ។ សម្រាប់គម្រោង "តួនាទីយុវជនកំពុងផុសឡើងនៅក្នុងសកម្មភាពនយោបាយ និងសេដ្ឋកិច្ច" អ្នកស្រាវជ្រាវកំពុងធ្វើការកំណត់អ្នកផ្ដល់ព័ត៌មានគន្លឹះ។ សម្រាប់គម្រោង "ការតភ្ជាប់អភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម" ក្រុមស្រាវជ្រាវបានបញ្ចប់ការសិក្សាលើឯកសារមានស្រាប់ និងកំពុងចងក្រងរបាយការណ៍។

គម្រោង "រឿងល្អទាំងអស់ មិនមែនសុទ្ធតែដើរស្របគ្នានោះទេ៖ ការវិភាគពីភាពប្រទាំងប្រទើសគ្នារវាង ការកសាងសន្តិភាពនឹងប្រជាធិបតេយ្យភាវូបនីយកម្ម" បានអនុវត្តឡើងក្រោមកិច្ចសហការជាដៃគូជាមួយ សាកលវិទ្យាល័យ Gothenburg ដើម្បីកំណត់ពី បែបបទ និងមូលហេតុ ដែលទំនាស់ផុសឡើងក្នុងរយៈពេលខ្លី និងវែង បន្ទាប់ពីមាន ឬក៏អាចកើតឡើងពីអន្តរាគមន៍ខាងការកសាងសន្តិភាព ហើយអត្ថបទទស្សនាវដ្ដីផ្អែកលើគម្រោងនេះដំបូង កំពុងតាក់តែងបញ្ចប់ សម្រាប់ការចេញផ្សាយនៅខែកញ្ញា។

គម្រោងពីរកំពុងស្ថិតក្នុងដំណាក់កាលរចនារៀបចំ។ គម្រោង "រដ្ឋកម្ពុជា៖ តើមានលក្ខណៈល្អយ៉ាងណាសម្រាប់អភិវឌ្ឍន៍?" មានគោលដៅវាយតម្លៃពី ផលប៉ះពាល់នៃកំណែទម្រង់អភិបាលកិច្ចទៅលើសមត្ថភាពស្ថាប័នរបស់រដ្ឋ ដើម្បីជំរុញការអភិវឌ្ឍ ដោយប្រើប្រាស់គំរូរដ្ឋសម្រាប់អភិវឌ្ឍន៍ ជាក្របខ័ណ្ឌនៃការវិភាគ។ គម្រោង "ដំណោះស្រាយនយោបាយ និងកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា" ដែលបានចុះកិច្ចសន្យាស្រាវជ្រាវជាមួយ មជ្ឈមណ្ឌលសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពរដ្ឋ និងការអភិវឌ្ឍសម្រាប់គ្រប់គ្នា នៃសាកលវិទ្យាល័យ Manchester គឺជាផ្នែកមួយនៃការសិក្សាពហុប្រទេសដែលប្រើប្រាស់ ការវិភាគពីដំណោះស្រាយនយោបាយ ដើម្បីស្វែងយល់ពីល្បឿនអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃប្រទេសនីមួយៗ។

**កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់** (ETRC)

ក្រុមស្រាវជ្រាវបន្តអនុវត្ត និងរាយការណ៍ពី "អង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះ" និង "អង្កេតប្រចាំខែលើថ្លៃទំនិញតាមខេត្ត"។ អត្ថបទវិភាគចំនួនប្រាំបីនៃគម្រោង "វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា" និងរបាយការណ៍ស្ដីពី "ឧបសគ្គរាំងស្ទះកំណើនសេដ្ឋកិច្ចនៅកម្ពុជា៖ វិធីសាស្ត្រវិភាគពីកំណើន" ត្រូវបានចេញផ្សាយជាឯកសារពិភាក្សារបស់ CDRI ។

គម្រោងស្រាវជ្រាវរយៈពេលប្រាំឆ្នាំមួយ ទទួលបានជំនួយទ្រទ្រង់ពី Sida ស្ដីពីកំណើនសម្រាប់គ្រប់គ្នា កំពុងដំណើរការទៅមុខ និងចែកចេញជាប្រាំអនុគម្រោង៖ ១) កំណើនសេដ្ឋកិច្ច

ខ្ពស់ប្រកបដោយចីរភាព ២) កំណើនសេដ្ឋកិច្ច វិសមភាព និង ការកាត់បន្ថយភាពក្រីក្រ ៣) ការវាយតម្លៃពីភាពអំណោយផលដល់ជនក្រីក្រនៃគោលនយោបាយសារពើពន្ធ ៤) កំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និង ការកាត់បន្ថយភាពក្រីក្រ និង ៥) មធ្យោបាយដើម្បីសម្រេចបានកំណើនសម្រាប់គ្រប់គ្នា។ អត្ថបទស្តីពី "ការលើកកម្ពស់ពាណិជ្ជកម្មដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា" ដែលស្ថិតក្នុងអនុគម្រោង "កំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការកាត់បន្ថយភាពក្រីក្រ" កំពុងរៀបចំបោះពុម្ពផ្សាយជាឯកសារពិភាក្សា។ ការសិក្សាពីរផ្សេងទៀតស្តីពី "ភាពអំណោយផលដល់ជនក្រីក្រនៃគោលនយោបាយហិរញ្ញវត្ថុ" និង "គោលនយោបាយទីផ្សារពលកម្ម" កំពុងរចនារៀបចំឡើង។

កម្មវិធី ETRC ទទួលបានកិច្ចសន្យាស្រាវជ្រាវពីរគម្រោងគឺៈ "សន្តិសុខស្បៀង ផលប៉ះពាល់នៃហានិភ័យ និងវិបត្តិនានា និងគន្លងអភិវឌ្ឍន៍ជនបទនៅកម្ពុជា និងឡាវ" ដែលបានពីសាកលវិទ្យាល័យ Hannover និង "អង្កេតស្តីពីការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅកម្ពុជា" ដែលបានពី ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចនៅតំបន់អាស៊ានបូកបី (AMRO)។ ក្រុមស្រាវជ្រាវបានបញ្ចប់ការចុះសិក្សាដល់កន្លែងសម្រាប់គម្រោងទី១ ដែលគ្របដណ្តប់លើ ៦០០គ្រួសារ ក្នុង ៣០ភូមិ នៅខេត្តស្ទឹងត្រែង។ អង្កេតសម្រាប់គម្រោងទី២ កំពុងដំណើរការទៅមុខ ដោយមានការធ្វើសម្ភាសន៍ជាមួយ ១៥០០គ្រួសារ និង ៥០០ សហគ្រាសធុនតូច និងមធ្យម ក្នុង ១៧ភូមិ។ សំណើស្រាវជ្រាវស្តីពី "ចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជាៈ មូលហេតុ និងផលប៉ះពាល់លើភាពក្រីក្រ វិសមភាព និងផលិតភាព" បានទទួលការយល់ព្រមផ្តល់មូលនិធិពីអង្គការភាពជាដៃគូដើម្បីសិក្សាពីគោលនយោបាយសេដ្ឋកិច្ច (PEP) រួចហើយ។

នៅខែមិថុនាបណ្តាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គបានរៀបចំកិច្ចប្រជុំនៅរាជធានីភ្នំពេញដើម្បី១) បូកសរុបការស្រាវជ្រាវដំណាក់កាលទី១ ជាពិសេសលើរបាយការណ៍សំយោគ ២) កែសម្រួលផែនការស្រាវជ្រាវដំណាក់កាលទី២ ដោះស្រាយបញ្ហាខាងវិធីសាស្ត្រស្រាវជ្រាវ និងកង្វះថវិកា និង ៣) ពិភាក្សាពីសេចក្តីព្រាងអត្ថបទកំណត់គោលគំនិតសម្រាប់ជំហានបន្ទាប់ និងដំណើរការទៅអនាគត។

**កម្មវិធីធនធានធម្មជាតិ និង បរិស្ថាន** (NRE)

គម្រោងស្រាវជ្រាវប្រាំមួយកំពុងដំណើរការទៅមុខ ក្នុងនោះ គម្រោងបីទទួលបានមូលនិធិពី Sida។ របាយការណ៍គម្រោង "ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងជីវភាពរស់នៅក្នុងប្រទេសកម្ពុជា" កំពុងកែសម្រួលដើម្បីចេញផ្សាយជាឯកសារពិភាក្សារបស់ CDRI។ ឯកសារពិភាក្សាស្តីពី "យេនឌ័រ និងអភិបាលកិច្ចទឹកៈ ការគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ" កំពុងកែសម្រួលឡើងវិញ និងរៀបចំដើម្បីបោះពុម្ពផ្សាយ។ សម្រាប់គម្រោង "សមត្ថភាពបន្សាំរបស់ប្រជាជនជនបទក្នុងតំបន់កសិអេកូឡូស៊ីចម្បងៗ" ក្រុមស្រាវជ្រាវកំពុងចុះសិក្សាដល់កន្លែង។

ការសិក្សាពីសមិទ្ធលទ្ធភាពសម្រាប់គម្រោង "ប្រទេសចិនឈានឡើងកម្រិតសាកលៈ ការសិក្សាប្រៀបធៀបពីទំនប់វារីអគ្គិសនីចិននៅទ្វីបអាហ្វ្រិក និងអាស៊ី" ដែលទទួលមូលនិធិពីក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ចនិងសង្គម (ESRC) កំពុងដំណើរការទៅមុខ។ លទ្ធផលស្រាវជ្រាវបឋមនៃគម្រោង "ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា" ដែលទ្រទ្រង់ដោយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) បានយកទៅរាយការណ៍ក្នុងសិក្ខាសាលាថ្នាក់តំបន់ស្តីពី ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹក ដែលរៀបចំដោយ IDRC នៅទីក្រុង Kathmandu ប្រទេសនេប៉ាល់ កាលពីថ្ងៃទី ១៨ ដល់ ២១ មិថុនាកន្លងទៅ ហើយ វិធីសាស្ត្រមានការចូលរួម និងកាត់បន្ថយទំហំ (participatory and downscaling) សម្រាប់ការវាយតម្លៃពីភាពងាយរងគ្រោះ និងភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុកំពុងសើរើពិនិត្យឡើងវិញ។ ក្រុមអ្នកស្រាវជ្រាវក៏កំពុងរៀបចំចងក្រងអត្ថបទសង្ខេបលើប្រទេសកម្ពុជា ស្តីពី "ទេសចរណ៍ កម្មន្តសាលកម្ម និងថាមពលៈ ឱកាស បញ្ហាប្រឈម និងការពាក់ព័ន្ធផ្នែកគោលនយោបាយនៅកម្ពុជា" ដោយប្រើប្រាស់ការសិក្សាពី "វិធីសាស្ត្រជាក់ស្តែង សម្រាប់ជួយទ្រទ្រង់ភាពប្រកួតប្រជែងនៃប្រទេសមានចំណូលទាប/មធ្យមកម្រិតទាប នៅក្នុងពិភពលោកដែលកំពុងមានកំហិតផ្នែកកាបូន"។

**កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ** (PARD)

ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងចំនួនប្រាំមួយ។ របាយការណ៍បញ្ចប់សម្រាប់គម្រោង "ការសិក្សាពីការរួមចំណែកនៃសេវាកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីកែលំអទំនាក់ទំនងខាងឧស្សាហកម្មនៅកម្ពុជាៈ ករណីរោងចក្រកាត់ដេរ" ខាងអង្គការមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺបានទទួលយក ហើយគម្រោងនេះក៏បានចប់សព្វគ្រប់។ សម្រាប់គម្រោង "ការកសាងគោលនយោបាយកសិកម្ម សម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅកម្ពុជា និងឡាវ" របាយការណ៍ករណីសិក្សាអំពីឥណទានកសិកម្ម ខ្សែចង្វាក់តម្លៃជី និងខ្សែចង្វាក់តម្លៃអង្ករ ខាងប្រធានគម្រោងនៅឯសាកលវិទ្យាល័យ Queensland កំពុងពិនិត្យឡើងវិញ រីឯរបាយការណ៍ស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យា ជិតចប់សព្វគ្រប់ហើយ។ ក្នុងដំណាក់កាលទី២ នៃគម្រោងខាងលើនេះ មានករណីសិក្សាពីរគឺ "ខ្សែចង្វាក់តម្លៃសត្វចិញ្ចឹម (គោក្របី)" និង "លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ" បានចាប់អនុវត្តហើយ។ ការចុះសិក្សាដល់កន្លែងដើម្បីប្រមូលទិន្នន័យសម្រាប់ការសិក្សាទ្រទ្រង់ដោយ Sida ស្តីពី "ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យា ទៅលើជីវភាពរស់នៅរបស់ម្ចាស់ដីតូចៗ" ត្រូវបានពន្យាពេល ព្រោះជិតដល់ពេលបោះឆ្នោតថ្នាក់ជាតិ។ របាយការណ៍សម្រេចស្តីពី "ការសិក្សាវាយតម្លៃគោលដើមលើ កម្មវិធីការជួយដោះស្រាយបញ្ហាភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី (HARVEST) ផ្តល់ហិរញ្ញប្បទានដោយ USAID" ខាងម្ចាស់ជំនួយបានទទួលយកហើយ។ គម្រោងស្រាវជ្រាវផ្តល់មូលនិធិ

ដោយ Sida ស្តីពី "ការសិក្សាពីយន្តកម្មតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មក្នុងវិស័យកសិកម្ម" បានចាប់ដំណើរការ។ ក្រុមអ្នកស្រាវជ្រាវ ក៏បានចាប់អនុវត្តគម្រោងថ្មីមួយស្តីពី "ស្ថានភាពនៃការអភិវឌ្ឍឧស្សាហកម្មជីនៅកម្ពុជា" ដែលជាការសិក្សាឆ្លងប្រទេសគ្របដណ្តប់លើ តំបន់អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង និងអាស៊ីកណ្តាល ក្រោមកិច្ចសន្យាធ្វើការស្រាវជ្រាវឲ្យ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) និងទទួលមូលនិធិពី USAID។ នៅខែឧសភា ក្រុមស្រាវជ្រាវកម្មវិធីនេះ បានចូលរួមក្នុងសិក្ខាសាលាបំផុសគំនិតមួយនៅរាជធានីភ្នំពេញ ជាមួយក្រុមស្រាវជ្រាវ ១១ប្រទេសផ្សេងទៀត។

**កម្មវិធីអភិវឌ្ឍន៍សង្គម** (SD)

កម្មវិធីនេះកំពុងដំណើរការគម្រោងចំនួនប្រាំបី។ គម្រោងស្រាវជ្រាវរយៈពេល៦ឆ្នាំស្តីពី "ការកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់" (ReBUILD) ដែលទទួលជំនួយទ្រទ្រង់ពី ក្រសួងអភិវឌ្ឍន៍អន្តរជាតិ(អង់គ្លេស) (DFID) បានជឿនលឿនទៅមុខច្រើនហើយ។ នាបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងប្រមូលទិន្នន័យសម្រាប់អនុគម្រោងទាំងបី ក្នុងនោះ គឺមាន ១) ឥទ្ធិពលនៃការផ្លាស់ប្តូរគោលនយោបាយហិរញ្ញប្បទានផ្នែកសុខភាពទៅលើ លំនាំចំណាយរបស់គ្រួសារក្រីក្រនៅកម្ពុជាក្នុងការថែទាំសុខភាព ២) គោលនយោបាយទាក់ទាញ និងរក្សាបុគ្គលិកសុខាភិបាលនៅតាមជនបទ និង ៣) ដំណើរការផ្លាស់ប្តូរក្នុងការរៀបចំកិច្ចសន្យាផ្តល់សេវា ក្នុងវិស័យសុខាភិបាលនៅកម្ពុជា"។

ការសិក្សាស្តីពី "ការលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារតាមរយៈការអប់រំ និងលើកកម្ពស់ជីវភាព" ដែលបានធ្វើឡើងដោយរួមសហការជាដៃគូជាមួយ អង្គការទស្សនពិភពលោក និងទទួលបានហិរញ្ញប្បទានពី ក្រសួងការងាររបស់សហរដ្ឋអាមេរិក កំពុងស្ថិតក្នុងដំណាក់កាលសិក្សាឯកសារមានស្រាប់ និងការរចនារៀបចំ។ ទិន្នន័យសម្រាប់គម្រោង "ការត្រួតពិនិត្យលទ្ធផលផ្នែកអនាម័យនៅកម្ពុជា" ដែលទទួលបានហិរញ្ញប្បទានពីមូលនិធិ Bill & Melinda Gates គឺបានប្រមូល និងធ្វើវិភាគហើយ។ពិធីសារស្រាវជ្រាវសម្រាប់គម្រោងទ្រទ្រង់ដោយUNICEF ស្តីពី "ការវាយតម្លៃបែបគុណភាពលើកម្មវិធីអាហារូបត្ថម្ភកុមារនៅកម្ពុជា" បានដាក់ជូនទៅគណៈកម្មការក្រមសីលធម៌ជាតិរួចហើយ ដើម្បីសុំការយល់ព្រម។ ក្រុមស្រាវជ្រាវបានចាប់អនុវត្តគម្រោងថ្មីមួយផ្តល់មូលនិធិដោយ Sida ស្តីពី "ការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម" ដើម្បីសិក្សាពីចំណងទាក់ទងរវាងការអប់រំថ្នាក់ខ្ពស់នឹងទីផ្សារពលកម្ម និងជួយបន្ស៊ីគ្នារវាងជំនាញដែលស្ថាប័នអប់រំថ្នាក់ខ្ពស់ផលិតចេញ នឹងជំនាញដែលសហគ្រាសនានាត្រូវការ។

គម្រោងស្រាវជ្រាវរួមគ្នាជាមួយកម្មវិធីផ្សេងៗទៀត រួមមានគម្រោង "ករណីសិក្សាពីការដាំដុះស្រូវតាមកិច្ចសន្យា" ដែលរំពឹងថានឹងចប់សព្វគ្រប់ក្នុងខែកក្កដាខាងមុខ, គម្រោងទ្រទ្រង់ដោយកម្មវិធីសិក្សាខ្សែចង្វាក់តម្លៃផ្នែកកសិកម្មនៅកម្ពុជា (CAVAC) ស្តីពី "ការវាយតម្លៃផលប៉ះពាល់នៃគម្រោងផ្តល់មូលនិធិដោយអង្គភាពស្តារនីតិសម្បទា (CARF)" ដែលកំពុងបង្ហើយរបាយការណ៍សម្រេច និងគម្រោង "ការលើកកម្ពស់អភិបាលកិច្ចទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ" ដែលកំពុងស្ថិតក្នុងដំណាក់កាលសិក្សាឯកសារមានស្រាប់និងរចនារៀបចំ។ ក្រុមស្រាវជ្រាវក៏បានបញ្ជូនលិខិតសម្តែងចំណាប់អារម្មណ៍ និងសំណើស្រាវជ្រាវជាច្រើន ទៅកាន់ដៃគូផ្តល់ជំនួយសំខាន់ៗផងដែរ។


## Cambodia Development Review—2013 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........................................................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........................................................................

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒ Other ..........................................................................

First name: .............................................. Last name: .............................................. Position: ..............................................

Organisation / Company: ..........................................................................

Address (CCC Box if applicable): ..........................................................................

City / Province: .............................................. Country: ..............................................

Telephone: .............................................. Fax: ..............................................

e-mail: .............................................. ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

នៅខែមេសា ២០១៣ វិទ្យាស្ថាន CDRI បានធ្វើការប្រជុំតុមូលមួយរាយការណ៍ពី បញ្ហាអភិវឌ្ឍន៍ចម្បងៗសម្រាប់ប្រទេសកម្ពុជាជូនលោកស្រី Rebecca Black ជាប្រធានបេសកកម្មជំនួយអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) នៅកម្ពុជា។ នៅខែឧសភា-មិថុនា CDRI បានជួប វិទ្យាស្ថានសភាកម្ពុជា ដើម្បីពិភាក្សាលើ កិច្ចសហការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ និងការផ្សព្វផ្សាយ និងធ្វើការប្រជុំតុមូលជាមួយ លោក Alassane Sow ជាអ្នកគ្រប់គ្រងប្រចាំប្រទេសនៃធនាគារពិភពលោក និង ឯ.ឧ Jean-François Cautain ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុប និង ក្រុមការងារអភិវឌ្ឍន៍របស់ស្ថានទូត ដើម្បីរាយការណ៍ពីវិស័យចម្បងៗដែល CDRI កំពុងធ្វើការ និងពិភាក្សាពីលទ្ធភាពរួមសហការជាដៃគូ។

នៅខែឧសភា ក្នុងការប្រជុំបូកសរុបប្រចាំឆ្នាំអំពី កិច្ចសហការជាដៃគូរវាង CDRI និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលជាអ្នកផ្តល់មូលនិធិក្នុងរយៈពេលវែង វិទ្យាស្ថាន CDRI បានរាយការណ៍ពី ការជឿនលឿនក្នុងវិស័យស្រាវជ្រាវជាអាទិភាពដែលទទួលបានជំនួយទ្រទ្រង់ពី Sida ពោលគឺ អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ កំណើនសម្រាប់គ្រប់គ្នា ការវិភាគភាពក្រីក្រ កសិកម្មនិងជីវភាពនៅជនបទ ដើម្បីមានកំណើនសម្រាប់ទាំងអស់គ្នា ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងជីវភាពរស់នៅ និងការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងអំពី លទ្ធផលសម្រេចបានក្នុងការគ្រប់គ្រងប្រតិបត្តិការដែលទទួលបានជំនួយទ្រទ្រង់ពី Sida។ ការបូកសរុបពាក់កណ្តាលអាណត្តិដោយឯករាជ្យនូវ ការប្រើជំនួយទ្រទ្រង់របស់ Sida សម្រាប់ឆ្នាំ២០១១-១៥ គ្រោងធ្វើឡើងនៅចុងឆ្នាំ២០១៣ ។ នៅខែឧសភា CDRI បានពិភាក្សាថែមទៀតជាមួយ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) អំពីការធ្វើកិច្ចសហការជាដៃគូដោយផ្តោតលើ វិស័យជាអាទិភាពរបស់ SDC នៅកម្ពុជា ពោលគឺ ការអភិវឌ្ឍកសិកម្ម ទីផ្សារពលកម្ម ការងារនិងការកសាងជំនាញ និងកិច្ចការពារខាងសង្គមកិច្ច។

នៅខែឧសភា លោកនាយកប្រតិបត្តិនៃ CDRI បានទៅចូលរួមសន្និសីទម៉ាក្រូសេដ្ឋកិច្ចអាស៊ី ស្តីពី អន្ទាក់នៃចំណូលមធ្យម និងអន្តរកាលសេដ្ឋកិច្ចនៅអាស៊ីបូព៌ា ដែលសហការរៀបចំធ្វើនៅក្រុងប៉េកាំងដោយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចចិននិងដេប៉ាតឺម៉ង់សិក្សាស្រាវជ្រាវអន្តរជាតិ នៃបណ្ឌិតសភានៃវិទ្យាសាស្ត្រសង្គមចិន (CASS)។ លោកបានបន្តចូលរួមក្នុងសិក្ខាសាលាស្រាវជ្រាវមួយស្តីពី គម្រោងស្រាវជ្រាវអន្តរកាលសេដ្ឋកិច្ចនៅអាស៊ីបូព៌ាដែលដឹកនាំដោយសាស្ត្រាចារ្យ Zhang Yunling នៃ CASS ហើយបានធ្វើបទបង្ហាញមួយស្តីពី សេដ្ឋកិច្ចតូចៗនិងអភិវឌ្ឍន៍បានតិចក្នុងអាស៊ាន៖ តម្រូវការ ឬ វិធីសាស្ត្រថ្មីមួយ។ នៅខែមិថុនា លោកបានទៅចូលរួមក្នុងកិច្ចប្រជុំកំពូលបើកដំណើរការក្រុមគិតគូរអាស៊ីនៅឯវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ីនៅក្រុងតូក្យូ ស្តីពី តួនាទីនៃក្រុមគិតគូរអាស៊ីនៅក្នុងសតវត្សរ៍អាស៊ីៈ ការចាប់យកឱកាស និងការគ្រប់គ្រងគ្រោះថ្នាក់។

នៅត្រីមាសទី២ នេះ លោកនាយកប្រតិបត្តិនៃ CDRI បានទៅចូលរួមក្នុងវគ្គជុំគំនិតស្តីពី សមាហរណកម្មទីផ្សារថាមពល (AEMI) ដែលជាគំនិតផ្តួចផ្តើមជួរទី២ រៀបចំឡើងដោយ មជ្ឈមណ្ឌលសិក្សាអាស៊ាន និង វិទ្យាស្ថានស្រាវជ្រាវថាមពល នៃសាកលវិទ្យាល័យ Chulalongkorn នៅក្រុងបាងកក ដើម្បីកំណត់ចក្ខុវិស័យនៃ AEMI ក្នុងក្របខ័ណ្ឌនៃ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ឆ្នាំ២០១៥ និងអាទិភាពស្រាវជ្រាវនានា។ លោកបានទៅចូលរួមផងដែរក្នុង សិក្ខាសាលាពិគ្រោះយោបល់រយៈពេល

*(តទៅទំព័រ ២១)*

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១៧ លេខ២ ខែមិថុនា ឆ្នាំ២០១៣

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ ខេង សេង
សហគ្រាសបោះពុម្ព សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ វិទ្យាស្ថាន CDRI ទេ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh